January-2009.qxd 12/28/2008 4:21 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣១ ខែមករា ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ

លេខ ១៧

## មាតិកា



កិច្ចសន្ទនាអន្តរសាសនានាំមកនូវ...
ទំព័រ ៧



សិក្ខាសាលានៃការផ្លាស់ប្តូរបទពិសោធន៏...
ទំព័រ ៨



បង្វិលពពិលក្នុងអាពាហ៏...
ទំព័រ ១៤

# ៧ មករា ខួប ៣០ឆ្នាំ នៃការបញ្ចប់របបប្រល័យពូជសាសន៍

ទំព័រទី១០_១១





SIPAR
សៀវភៅ
ធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ
និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh

កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# សារលិខិតអគ្គរាជទូតសម្តេចប៉ាប

## "សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឱ្យមនុស្សលោកដ៏ជាទីស្រលាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី" !



Picture: DR

"សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត និងសូមឱ្យមនុស្សលោកដ៏ជាទីស្រលាញ់របស់ព្រះអង្គបានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី" !

បុណ្យព្រះយេស៊ូប្រសូត ជាថ្ងៃមានអំណរសប្បាយ និងនាំមកនូវសេចក្តីសុខសាន្ត។ អ្នករាល់គ្នាអាចមើលឃើញគ្រប់ទីកន្លែង មនុស្សម្នាជូនពរគ្នាទៅវិញទៅមកទាំងនៅជិត និងទាំងនៅឆ្ងាយ សូមឱ្យបានសេចក្តីសុខសាន្ត និងអំណរសប្បាយ!។

ក្នុងនាមជាសាវ័ករបស់ព្រះអម្ចាស់ យើងមានទំនាក់ទំនងជាមួយអ្នកដទៃ ដោយក្តីសុខសាន្ត ដូចជាព្រះយេស៊ូបាននាំសេចក្តីសុខសាន្តមកពិភពលោកនេះ។ព្រះអង្គបានមកយកកំណើតជាមនុស្ស។ សេចក្តីសុខសាន្ត និងសេចក្តីអំណរសប្បាយទាំងនេះ មិនមែនសម្រាប់យើងជាគ្រីស្តបរិស័ទប៉ុណ្ណោះទេ តែក៏សម្រាប់អស់អ្នកដែលបានបើកចិត្តគំនិតទទួលដំណឹងល្អ អំពីកំណើតព្រះយេស៊ូ។ ជាច្រើនលើកច្រើនសា ទេវទូតយ៉ាងច្រើនកុះករចុះពីស្ថានបរមសុខ មកច្រៀងសរសើរព្រះជាម្ចាស់: "សូមលើកតម្កើងនូវសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយក៏សូមឱ្យមនុស្សលោកដ៏ជាទីស្រលាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី" (លូកា ២ : ១៤)។

"នៅពេលព្រះយេស៊ូកុមារប្រសូត សិរីរុងរឿងរបស់ព្រះអម្ចាស់ បានភ្លឺចិញ្ចែងចិញ្ចាចនៅក្នុងភូមិបេថ្លេហិម"។ នៅពេលនោះអ្នកគង្វាលដែលកំពុងតែឃ្វាលចៀមរបស់ពួកគេ ហើយបានមើលឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ទេវទូតព្រះជាម្ចាស់បានឈរនៅចំពីមុខពួកគេ និងសម្តែងនូវសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជុំវិញពួកគេ។ ពួកគេមានការភ័យខ្លាចជាខ្លាំង ហើយទេវទូតពោលទៅកាន់គេថា: "កុំខ្លាចអ្វីឡើយ! ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នា។ ដំណឹងល្អនេះនឹងធ្វើឱ្យអ្នករាល់គ្នាមានអំណរសប្បាយដ៏លើសលប់។ នៅថ្ងៃនេះនៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះសង្គ្រោះរបស់អ្នករាល់គ្នា បានប្រសូតហើយ គឺជាព្រះគ្រីស្តជាអម្ចាស់។ នេះគឺជាសញ្ញាសម្គាល់ឱ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នានឹងឃើញទារកមួយទើបនឹងកើតមក រុំដោយសំពត់ផ្តេកនៅក្នុងស្នូកសត្វ"។ ពេលនោះទេវទូតដ៏ច្រើនកុះករ ចុះពីស្ថានបរមសុខមករួមជាមួយទេវទូតនោះ និងច្រៀងសរសើរព្រះជាម្ចាស់ថា: "សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឱ្យមនុស្សលោកដ៏ជាទីស្រលាញ់របស់ព្រះអង្គបានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី" (លូកា ២៩ : ១៤)។

ខ្ញុំសរសេរអត្ថបទនេះ គឺនៅទល់មុខរូបគំរូស្នូកដាក់ព្រះកុមារយេស៊ូដ៏ស្រស់ស្អាតនេះ ដែលជាស្នាដៃសិល្បៈណេប៉ូលីឡាំង ដែលតាំងនៅលើជញ្ជាំងនៃនិវេសនដ្ឋានអគ្គរាជទូតសម្តេចប៉ាបនៅទីក្រុងបាងកក។ បុណ្យព្រះយេស៊ូប្រសូតគឺសម្រាប់ទាំងអស់គ្នា គឺជាថ្ងៃដែលមានអំណរសប្បាយ និងសេចក្តីសុខសាន្តដែលបានទទួលអំពីព្រះយេស៊ូគ្រីស្ត។ ខ្ញុំមានអំណរសប្បាយ និងចែករំលែកនូវសេចក្តីសុខសាន្តនេះ ជាមួយបងប្អូនទាំងអស់គ្នា។ បុណ្យព្រះយេស៊ូប្រសូតជាពេលវេលារំលឹកយើង ឱ្យដឹងអំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដែលមានចំពោះយើងទាំងអស់គ្នា។ ចូរយើងទាំងអស់គ្នា! មានអំណរសប្បាយចំពោះព្រះហឫទ័យសប្បុរសដ៏ទូលំទូលាយរបស់ព្រះអង្គ។

ជារៀងរាល់ឆ្នាំ អ្នកនាំសារបានផ្តល់ឱកាសដ៏វិសេសវិសាលចំពោះរូបខ្ញុំដើម្បីសួរសុខទុក្ខចំពោះបងប្អូនអ្នកអាន និងបងប្អូនគ្រីស្តបរិស័ទដទៃទៀត។ ស្ថិតក្នុងឱកាសជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតនេះ ខ្ញុំសូមសម្តែងនូវអំណររីករាយអស់ពីចិត្ត និងក៏សូមប្រសិទ្ធពរជូនបងប្អូន និងក្រុមគ្រួសារទាំងអស់។ សូមឱ្យពន្លឺនៃសេចក្តីសុខសាន្តដ៏ចិញ្ចែងចិញ្ចាចបំភ្លឺចិត្តគំនិត និងត្រួសត្រាយផ្លូវដល់បងប្អូន។ ខណៈយើងទាំងអស់កាន់តែខិតជិតមកដល់ឆ្នាំ២០០៩ ខ្ញុំសូមប្រសិទ្ធពរដល់បងប្អូនដោយចិត្តស្មោះសរ ឱ្យជួបតែសុភមង្គល និងភាពចម្រុងចម្រើនក្នុងឆ្នាំថ្មី២០០៩។ ខ្ញុំសូមប្រសិទ្ធពរឱ្យបងប្អូនមានអំណរសប្បាយក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតឆ្នាំនេះ។

**សាលវ៉ាទ័រ ពេណ្ណាស៊ីអូ ដ៏ឧត្តុង្គឧត្តម!**



# វិចារណកថា

## ៣០ឆ្នាំ ក្រោយរបបវាលពិឃាតបានបញ្ចប់



Photo : L. Samphors

លោកលី សុវណ្ណា ចាងហ្វាងការផ្សាយអ្នកនាំសារ

៧ មករា ១៩៧៩ ជាថ្ងៃបើកទំព័រប្រវត្តិសាស្ត្រកម្ពុជាជាថ្មីម្តងទៀត បន្ទាប់ពីជីវិតដែលពោរពេញដោយភាពសោកសង្រេង និងទុក្ខវេទនា ក្នុងរបបវាលពិឃាតពីឆ្នាំ១៩៧៥-១៩៧៩។ ប៉ុន្តែនៅមានមតិពីរផ្ទុយគ្នា។ មតិទី១ ៧ មករា ជាថ្ងៃដែលនាំប្រជាជនកម្ពុជាឱ្យរួចផុតអំពីការកាប់សម្លាប់ និងទារុណកម្មដ៏យង់ឃ្នងរបស់បនប្រល័យពូជសាសន៍ ឬថ្ងៃកំណើតទី២ របស់ប្រជាជន។ មតិទី២ ជាថ្ងៃដែលប្រទេសកម្ពុជាទទួលរងនូវការលុកលុយរបស់កងទ័ពវៀតណាម។

ក្រោយថ្ងៃ៧ មករា ប្រទេសកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមដែលបង្ហូរឈាមរវាងខ្មែរ និងខ្មែរបន្តទៀត។ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ មេដឹកនាំខ្មែរគ្រប់ភាគី ក៏ចុះហត្ថលេខាដើម្បីសន្តិភាពក្នុងឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ព្រះរាជាណាចក្រទី២ និងបាវចនាជាតិបានកើតឡើងវិញ។ ទោះបីជាយ៉ាងនេះ ប្រទេសកម្ពុជា មិនទាន់ទទួលសន្តិភាពទាំងស្រុងនោះទេ ព្រោះនៅមានតំបន់ត្រួតត្រាពីរប្រឆាំងគ្នានៅឡើយ។

នៅឆ្នាំ១៩៩៨ដោយនយោបាយឈ្នះៗរបស់សម្តេចហ៊ុន សែន តំបន់ត្រួតត្រានេះ ត្រូវបានរលាយចូលគ្នាតែមួយ ដែលចាប់ពីពេលនោះមក ប្រជាជនកម្ពុជាទទួលបានសន្តិភាពទាំងស្រុង។ សព្វថ្ងៃ ទោះបីមានមតិប្រឆាំងនឹង៧ មករា តែសេចក្តីពិតនៅតែជាសេចក្តីពិត។ ប្រជាជនបានទទួលស្គាល់ ហើយអន្តរជាតិក៏ទទួលស្គាល់ដែរថា ប៉ុល ពត ជាបនប្រល័យពូជសាសន៍ ព្រមទាំងបានបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាជនកម្ពុជាដែលរងគ្រោះផងដែរ។

ចំពោះការអភិវឌ្ឍន៍ ប្រទេសកម្ពុជាក៏បានរំកិលខ្លួនបន្តិចម្តងៗចាកចេញពីភាពក្រីក្រ។បើតាមស្ថិតិចុងក្រោយភាពក្រីក្រក្នុងប្រទេសកម្ពុជានៅសល់ប្រមាណជាង ៣០% ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា នៅមានបញ្ហាជាច្រើនដែលរដ្ឋាភិបាលត្រូវដោះស្រាយដូចជាការបន្តកាត់បន្ថយភាពក្រីក្រ កំណែទម្រង់សេវាសាធារណៈ និងអភិបាលកិច្ចល្អ ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ... ដែលទាំងនេះជាចំនុចក្តៅក្នុងអាណត្តិទីបួននេះ។


**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក./ ២៥-មិថុនា-២០០៧



**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងរ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។


## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក


**សេវាកម្មជាទីគាប់ចិត្ត!** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។


**សារសម្រាប់មិត្តអ្នកអាន!**

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ផ្តល់មតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវការឆ្លើយតបដោយក្តីរីករាយ។



**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី ១៦ រួចមើលជំនួយគំនិតនេះ៖**


**សេចក្តីជូនដំណឹង!** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។

January-2009.qxd 12/28/2008 4:21 PM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

**ព្រះយេស៊ូសម្ដែងព្រះអង្គឱ្យសាសន៍ដទៃ (ថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៩)**

*"សាសន៍ដទៃមានសិទ្ធិចូលរួមក្នុងអង្គព្រះគ្រីស្ត"*

(រ៉ូម ៣,៦) គម្ពីរដំណឹងល្អថ្ងៃនេះមានពីរក្រុម ក្រុមមួយជា"ប្រជារាស្ត្ររបស់ព្រះជាម្ចាស់"ដែលមានទាំងស្ដេចបូជាចារ្យ និងធម្មាចារ្យ ។ ពួកគេស្មានថា ខ្លួនជាមនុស្សសុចរិត មិនត្រូវស្វែងរកព្រះគ្រីស្ត ដែលទើបប្រសូតមកទេ។ ក្រុមមួយទៀតគឺពួកហោរាចារ្យជាសាសន៍ដទៃ ដែលជនជាតិយូដាតែងចាត់ទុកជាអ្នកបាប ។ តែក្រុមអ្នកបាបនេះយកចិត្តទុកដាក់ស្វែងរកសញ្ញាសម្គាល់អំពីព្រះគ្រីស្ត និងរកព្រះអង្គឃើញ ។ យើងជាគ្រីស្តបរិស័ទប្រៀបខ្លួនទុកជានរណា? កុំអួតថា យើងមានជំនឿហើយ! យើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ហើយ! យើងមិនដែលជឿគ្រប់គ្រាន់ទេ! យើងក៏មិនដែលស្គាល់ព្រះបិតាគ្រប់គ្រាន់ដែរ ។ សូមយើងយកចិត្តទុកដាក់សង្កេតមើលសញ្ញាសម្គាល់របស់ព្រះគ្រីស្ត ដែលទាក់ទាញអ្នកកាន់សាសនាដទៃឱ្យស្គាល់ព្រះអង្គសព្វថ្ងៃនេះផង ។

**ព្រះយេស៊ូទទួលពិធីជ្រមុជទឹក (ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៩)**

*"ព្រះយេស៊ូទតឃើញផ្ទៃមេឃរហែក ហើយព្រះវិញ្ញាណយាងមកសណ្ឋិតលើព្រះអង្គ"* (ម៉ាកុស១,៧-១១)

លោកយេស៊ូជាមនុស្សធម្មតា "លើកលែងតែមិនដែលប្រព្រឹត្តបាបប៉ុណ្ណោះ"។ លោកមកទទួលពិធីជ្រមុជទឹក ដូចអ្នកស្រុកឯទៀតៗ គឺលោកចង់ចូលរួមជាមួយក្រុមដែលរង់ចាំព្រះគ្រីស្ត ។ អ្នកនិពន្ធគម្ពីរដំណឹងល្អយល់ឃើញថា នៅពេលនោះ លោកយេស៊ូត្រាស់ដឹង គឺព្រះជាម្ចាស់សម្ដែងឱ្យលោកជ្រាបថា លោកជាព្រះគ្រីស្តដែលយាងមកណែនាំមនុស្សលោកឱ្យមានទំនាក់ទំនងជាមួយព្រះបិតា គឺផ្ទៃមេឃដែលគេចាត់ទុកជាទីលំនៅរបស់ព្រះជាម្ចាស់ "រហែក" តាមសំណូមពររបស់ព្យាការី ដូចវាំងននក្នុងព្រះវិហារ "រហែកជាពីរ" នៅពេលព្រះអង្គសោយទិវង្គត ។ ព្រះអង្គណែនាំមនុស្សលោកឱ្យមានទំនាក់ទំនងជាមួយព្រះបិតា ដោយបូជាព្រះជន្មដូចអ៊ីសាក គឺជា"បុត្រដ៏ជាទីស្រឡាញ់" របស់លោកអាប្រាហាំ ដែលជា"ទីគាប់ព្រះហឫទ័យ" ព្រះជាម្ចាស់ ។ ព្រះអង្គសង្គ្រោះមនុស្សបានដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណ ។

**ថ្ងៃអាទិត្យទី ២ ក្នុងរដូវធម្មតា ឆ្នាំ ខ (ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៩)**

*"តើអ្នករកអ្វី ?"* (យ៉ូហាន ១,៣៥-៤២)

លោកយ៉ូហានបាទីស្ដជានិមិត្តរូបអំពីសាវ័កដែលប្រកាសជំនឿ ។ ក្រោយពេលព្រះយេស៊ូសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង លោកប្រកាសថាព្រះយេស៊ូដកបាបពីមនុស្សលោកដូចកាលពីដើមជនជាតិយូដាធ្លាប់បូជាកូនចៀម ដើម្បីឱ្យបានរួចពីបាប ។ ព្រះយេស៊ូសួរអ្នកដែលចង់តាមព្រះអង្គថា "តើអ្នករកអ្វី?"។ ព្រះអង្គសួរយើងម្នាក់ៗដែរថា "តើអ្នករកអ្វី?" តើអ្នកទៅជាគ្រីស្តបរិស័ទមកពីខ្លួនចង់រកប្រយោជន៍ខ្លួនដោយសូមឱ្យព្រះសហគមន៍ជួយនាំទៅមន្ទីរពេទ្យ ចង់បានលុយ ចង់បានការងារ ចង់រៀនសូត្រ-ល-ឬ? សាវ័កពីរនាក់ជាគំរូសម្រាប់យើង គឺគេចង់ដឹងថា តើព្រះអង្គនៅឯណា? គឺក្រោយពេលព្រះយេស៊ូសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង ។ ព្រះយេស៊ូគង់នៅជាមួយព្រះបិតា និងជាមួយយើង ។ ព្រះអង្គណែនាំយើងទៅកាន់ព្រះបិតា ។ នេះគឺជាអំណរសប្បាយដែលយើងចង់ចែករំលែកដល់អ្នកដទៃដែរ ។ ក្នុងសប្ដាហ៍ខាងមុខ យើងរួមជាមួយគ្រីស្តបរិស័ទគ្រប់និកាយ ។ សូមព្រះបិតាបង្រួមយើងជាមហាគ្រួសារតែមួយ ។

**ថ្ងៃអាទិត្យទី៣ ក្នុងរដូវធម្មតា ឆ្នាំ ខ ឬគ្រីស្តទូតប៉ូលប្រែចិត្តគំនិត (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨)**

*"ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អ"* (ម៉ាកុស ១,១៤-២០)

តើយើងត្រូវប្រកាសដំណឹងល្អអ្វី? តាមធម្មតា "ដំណឹងល្អ" នាំសេចក្ដីសុខសាន្តដល់អ្នកទទួល ។ តើបងប្អូនសប្បាយយ៉ាងណាដោយបានទៅជាគ្រីស្តបរិស័ទ? គ្រីស្តទូតប៉ូលប្រកាសដំណឹងអំពីព្រះហឫទ័យអាណិតមេត្តាប្រោសប្រណីដ៏លើសលប់របស់ព្រះបិតា ទៅកាន់មនុស្សគ្រប់ជាតិសាសន៍ដោយមិនគិតអំពីប្រពៃណីសាសនា ឬបុណ្យបាបឡើយ ។ គ្រីស្តទូតប្រកាសថា: "ព្រះជាម្ចាស់មិនប្រោសមនុស្សឱ្យបានសុចរិតដោយគេប្រព្រឹត្តតាមធម្មវិន័យលោកម៉ូសេទេ គឺគេបានសុចរិតដោយមានជំនឿលើព្រះយេស៊ូ ដែលបូជាព្រះជន្មសម្រាប់ខ្លួន" បានន័យថា ជីវិតរបស់មនុស្សយើងមានតម្លៃព្រោះព្រះគ្រីស្តស្រឡាញ់រហូតដល់បូជាព្រះជន្មសម្រាប់យើង ។ យើងក៏រួមជាមួយព្រះគ្រីស្តដែលមានព្រះជន្មក្នុងរូបយើងដែលសុខចិត្តបូជាជីវិតសម្រាប់អ្នកដទៃដូចគ្រីស្តទូតប៉ូលសរសេរថា: "មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្តទេតើ ដែលមានព្រះជន្មរស់នៅក្នុងខ្ញុំ ។ ខ្ញុំជាប់ឆ្កាងជាមួយព្រះគ្រីស្តហើយ ។ ខ្ញុំក៏លែងមានទាក់ទាមអ្វីនឹងពិភពលោកទៀតដែរ" ។

*(អ្នកនាំសារ ខែមករា ២០០៩ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងស្វ៊ែ)*

## យើងអាន


Photo: DR

**សួស្ដីប្អូនៗ**

សូមយើងទាំងអស់គ្នារិះគិតអំពីកំណើតព្រះយេស៊ូនាឱកាសដែលយើងកំពុងរីករាយនឹងបុណ្យព្រះយេស៊ូប្រសូត និងចូលឆ្នាំសកលថ្មី។ ព្រះជាម្ចាស់បានជ្រើសរើសប្អូនម្នាក់ៗ តាមឈ្មោះរៀងៗខ្លួន ដើម្បីឱ្យប្អូនធ្វើជាបុត្រធីតារបស់ព្រះអង្គ និងឱ្យយើងប្រកាសដំណឹងល្អរបស់ព្រះអង្គទៅគ្រប់ទីកន្លែងដែរ។

ក្នុងលិខិតរបស់គ្រីស្តទូតប៉ូល បានសរសេរថា ដំណឹងល្អនេះគឺជាការសន្យារបស់ព្រះជាម្ចាស់ជាមួយមនុស្សលោកតាមរយៈពួកព្យាការីរបស់ព្រះអង្គ គឺព្រះបុត្រាចាប់កំណើតជាមនុស្សដូចប្អូនមានសាច់ មានឈាមក្នុងខ្សែរាជវង្សរបស់ព្រះបាទដាវីឌ។ ដូចប្អូនៗបានដឹងរួចមកហើយ គឺព្រះយេស៊ូនេះតែម្ដង។ ព្រះយេស៊ូបានប្រសូតជាមនុស្សដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ និងតាមរយៈព្រះនាងព្រហ្មចារិនីម៉ារីជាម្ដាយ និងលោកយ៉ូសែបជាឪពុកចិញ្ចឹម នៅក្នុងភូមិបេថ្លេហិមជាភូមិកំណើតរបស់ស្ដេចដាវីឌ។

សូមប្អូនសាកល្បងនិទានរឿងកំណើតព្រះយេស៊ូប្រាប់មិត្តរបស់ប្អូន។ ក្រោយនិទានចប់ហើយ តើប្អូនមានអារម្មណ៍យ៉ាងដូចម្ដេចដែរ? តើប្អូនមានអារម្មណ៍សប្បាយឬទេ?

ពិតណាស់! ពេលយើងទាំងអស់គ្នានិទានរឿងព្រះយេស៊ូប្រសូត គឺធ្វើឱ្យយើងសប្បាយរីករាយ ព្រោះព្រះយេស៊ូនាំអំណរសប្បាយមកឱ្យប្អូន។ នៅពេលនេះ ព្រះយេស៊ូកើតក្នុងគ្រួសារដូចប្អូនៗ។ ក្នុងគម្ពីរអេសាយបញ្ជាក់ថា: "មើលនាងព្រហ្មចារីនឹងមានផ្ទៃពោះប្រសូតបានបុត្រាមួយ គេនឹងហៅបុត្រនោះថា "អេម៉ាណូអែល" មានន័យព្រះជាម្ចាស់គង់ជាមួយយើង"។ ដូច្នេះព្រះយេស៊ូគង់នៅជាមួយប្អូនគ្រប់ពេលវេលា។

នៅក្នុងឆ្នាំសកលថ្មីនេះ សូមប្អូនៗជូនពរគ្នាទៅវិញទៅមកក្នុងនាមព្រះកុមារយេស៊ូ ដែលបានកើតជាមនុស្ស។ សូមយកចិត្តទុកដាក់ស្រឡាញ់មិត្តរបស់ខ្លួនស្មោះត្រង់ កុំបង្កជម្លោះរវាងគ្នានិងគ្នា។ ចូរប្អូនខិតខំរៀនសូត្រ ស្ដាប់បង្គាប់ឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូ និងធ្វើជាកុមារសុភាព ដូចព្រះកុមារយេស៊ូដែរ។

លី សុវណ្ណា



# ព័ត៌មានទូទៅ

## នាយករដ្ឋមន្ត្រី ផ្ដល់អនុសាសន៍ក្នុងការពង្រឹងវិន័យសង្ឃ និងវិមជ្ឈការអំណាច

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អនុសាសន៍នាឱកាសប្រារព្ធបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃនៅទូទាំងប្រទេសលើកទី១៧ នាថ្ងៃ១៨ ធ្នូថា ដើម្បីបំបាត់បុគ្គលសង្ឃខិលខូចខ្លះៗ គេគួរយកចិត្តទុកដាក់ពង្រឹងវិន័យសង្ឃឱ្យល្អ ។ សម្ដេចហ៊ុន សែន ស្នើសុំឱ្យព្រះសង្ឃទាំងអស់គោរព និងអនុវត្តន៍តាមតួនាទី ដែលមានចែងក្នុងច្បាប់ដោយចាប់ផ្ដើមពង្រឹងពីមន្ត្រីសង្ឃថ្នាក់លើទៅមុន ។ សម្ដេចក៏បានស្នើសុំឱ្យធ្វើវិមជ្ឈការអំណាចព្រះសង្ឃ ដើម្បីឱ្យមន្ត្រីសង្ឃថ្នាក់ក្រោមមានភាពងាយស្រួលក្នុងការដោះស្រាយពេលមានអធិករណ៍រវាងព្រះសង្ឃកើតឡើង ។ សម្ដេចហ៊ុន សែន បានពោលថា: "ខ្ញុំភ័យជាងគេ គឺព្រះសង្ឃទាស់គ្នា តែព្រះសង្ឃទាស់គ្នាពិបាករត់គេច ដូចរត់គេចគ្រាប់ប្លោងអឺចឹង" ។

## កម្ពុជាផ្ទុះជំងឺគ្រុនផ្ដាសាយបក្សីជាថ្មី

កម្ពុជារកឃើញនូវករណីជំងឺគ្រុនផ្ដាសាយបក្សីឆ្លងមកមនុស្សជាថ្មី កើតមានលើយុវជនអាយុ ១៩ឆ្នាំ រស់នៅខេត្តកណ្ដាលនាដើមខែធ្នូ ។ នេះជាករណីទី៨ហើយដែលអាជ្ញាធរប្រកាសឱ្យដឹង ។ សេចក្ដីប្រកាសព័ត៌មានអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជាបានបញ្ជាក់ថា យុវជនរូបនេះត្រូវបាន រកឃើញថា មានមេរោគ H5N1 ក្រោយពេលបញ្ចប់លទ្ធផលវិភាគ ដោយវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ កាលពីថ្ងៃទី១១ ធ្នូ។ ប្រភពនេះបញ្ជាក់ទៀតថា អ្នកជំងឺកំពុងឋិតនៅក្រោមការត្រួតពិនិត្យពីមន្ត្រីសុខភាព និងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ លោកលី សុវណ្ណ អនុប្រធាននាយកដ្ឋានប្រឆាំងជំងឺឆ្លងនៃក្រសួងសុខាភិបាល មានប្រសាសន៍ថា យុវជននេះមានសុខភាពល្អប្រសើរជាងមុន ។ កម្ពុជាបានឆ្លងវីរុសគ្រុនផ្ដាសាយបក្សីតាំងពីឆ្នាំ២០០៥មក និងបានសម្លាប់មនុស្ស ៧នាក់ ដែលចុងក្រោយ គឺកុមារីអាយុ ១៣ឆ្នាំ បានស្លាប់ កាលពីខែមេសា ២០០៧ ។


Photo: L. Samphors

## ប្រទេសកម្ពុជាទទួលបានជំនួយជិតមួយពាន់លានដុល្លារ

ប្រទេសផ្ដល់ជំនួយបានសន្យានឹងផ្ដល់ជំនួយអភិវឌ្ឍន៍ និងប្រតិបត្តិការចំនួន ៩៥១,៥ លាន ដុល្លារអាម៉េរិកដល់កម្ពុជាសម្រាប់ឆ្នាំ២០០៩ ។ ថវិកានេះអាចនឹងឡើងដល់មួយពាន់លានដុល្លារ ព្រោះមានប្រទេសមួយចំនួនពុំទាន់អាចប្រាប់ឱ្យដឹង ក្នុងនោះមានប៉ែលហ្ស៊ិក និងសហរដ្ឋអាម៉េរិកផងដែរ ។ លោកគាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រាប់ក្នុងសន្និសីទកាសែត កាលពីថ្ងៃទី៥ ធ្នូ គឺជាថ្ងៃបញ្ចប់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍ កម្ពុជាលើកទី២ ថា ចិនបាននាំមុខគេក្នុងការផ្ដល់ជំនួយមានទឹកប្រាក់ ២៥៧លានដុល្លារ សហគមន៍អឺរ៉ុប ២១៤លានដុល្លារ និងជប៉ុន ១១៣លានដុល្លារ ។ លោកបញ្ជាក់ទៀតថា អំណោយច្រើននៅពេលនេះ ក៏ដោយសារតែប្រទេសផ្ដល់ជំនួយមើលឃើញកម្ពុជាមានស្នាដៃពិតប្រាកដក្នុងការអភិវឌ្ឍន៍ ។ កាលពីឆ្នាំមុន ប្រទេសកម្ពុជាទទួលបានទឹកប្រាក់ជំនួយត្រឹមតែ ៦៩០ លានដុល្លារតែប៉ុណ្ណោះ ។

**រស់ ឌីណា**

## គុយបារួចពីទណ្ឌកម្មសេដ្ឋកិច្ចរបស់អាម៉េរិក


Photos : DR

ប្រទេសគុយបា ដែលស្ថិតនៅក្នុងការហ៊ុមព័ទ្ធសេដ្ឋកិច្ច ពីអាម៉េរិករាប់សិបឆ្នាំ តាំងពីសម័យសង្គ្រាមត្រជាក់ គឺទំនងជារើរួចពីការហ៊ុមព័ទ្ធនេះ ក្រោយពេលដែលប្រទេសប្រជាជាតិនៅអាម៉េរិកឡាទីនទទួលគុយបាជាសមាជិក ក្នុងចំណោមសមាជិកសរុប ២៣ប្រទេស ។ ទីភ្នាក់ងារព័ត៌មានបារាំងរាយការណ៍កាលពីថ្ងៃទី១៦ ធ្នូ ថា គុយបាត្រូវបានទទួលស្គាល់ថា ជាសមាជិករបស់ប្រជាជាតិអាម៉េរិកឡាទីននៅក្នុងកិច្ចប្រជុំកំពូលមួយនៅប្រទេសប្រេស៊ីល ។ លោករ៉ាអូល កាស្ត្រូ ប្រធានាធិបតីនៃប្រទេសគុយបា និយាយថា នេះគឺជាជោគជ័យដែលមិនអាចកាត់ថ្លៃបានសម្រាប់ប្រទេសរបស់លោក ។ លោកហ៊្គោ ឆាវេស ប្រធានាធិបតីប្រទេសវេណេហ្ស៊ូអេឡា ដែលតែងរិះគន់ ពីគោលនយោបាយអាម៉េរិកថា វត្តមានរបស់គុយបាគឺជាការសម្រេចដ៏យុត្តិធម៌មួយ ។ មុនឆ្នាំ១៩៦២ ប្រទេសគុយបាគឺជាសមាជិកនៃអង្គការរដ្ឋនៅអាម៉េរិក ប៉ុន្តែត្រូវបណ្ដេញចេញ ដោយសារបញ្ហារំលោភលទ្ធិប្រជាធិបតេយ្យ ។ លោករ៉ាអូល អះអាងថា ការបណ្ដេញនេះ វាលែងសំខាន់ហើយ ។ នៅពេលនេះ គុយបាគឺជាប្រទេសនៅក្នុងតំបន់អាម៉េរិកឡាទីន ។

## ទេសចរណ៍ប្រមាណ ៣០នាក់ស្លាប់ដោយគ្រោះថ្នាក់រថយន្ត



សារព័ត៌មានរ៉យទ័រ រាយការណ៍ឱ្យដឹងថា កាលពីថ្ងៃទី១៦ ខែធ្នូ មានឧប្បត្តិហេតុរថយន្តបើកខុសពីផ្លូវមួយ និងរេចង្កូតធ្លាក់ទៅក្នុងជ្រោះនៅក្នុងប្រទេសអ៊ីស្រាអែល បានសម្លាប់ជីវិតមនុស្ស រហូតដល់ ៣០នាក់ ដោយក្នុងនោះ ភាគច្រើនគឺជាជនជាតិរុស្ស៊ី ។ ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំនៅប្រទេសអ៊ីស្រាអែល អះអាងដែរថា មនុស្សប្រមាណ ៣០នាក់ បានត្រូវរាយការណ៍ថា ស្លាប់នៅក្នុងនោះ ២៤នាក់ គឺជាជនជាតិរុស្ស៊ី ហើយមនុស្ស ២១នាក់ផ្សេងទៀតរងរបួស ។ រីឯអាជ្ញាធរអ៊ីស្រាអែល ប្រាប់ឱ្យដឹងថា នេះជាឧប្បត្តិហេតុនៃគ្រោះថ្នាក់ចរាចរណ៍ដ៏អាក្រក់ជាងគេនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ តាមការគ្រោងទុក អ្នកទេសចរណ៍ទាំងអស់នោះកំពុងធ្វើដំណើរទៅកាន់តំបន់ទេសចរណ៍ដ៏ល្បីឈ្មោះ របស់ប្រទេសអ៊ីស្រាអែល គឺរមណីយដ្ឋានអេឡាត (Eilat) ដែលស្ថិតជាប់នឹងព្រំដែនរវាងប្រទេសហ្ស៊កដង់ និងអេស៊ីប គឺជាកន្លែងដែលពួកគេរំពឹងថា នឹងអាចមើលថ្ងៃលិច និងទេសភាពនាឆ្នេរខ្សាច់ដ៏ត្រកាល ។

**ខាន់ ភីរម្យ**

January-2009.qxd 12/28/2008 4:21 PM Page 6



# សេចក្តីសង្ឃឹមថ្មីសម្រាប់មនុស្សចាស់ជរានៅកំពង់ចាម

**លី សុវណ្ណា**

អគារថ្មីមួយខ្នង ត្រូវបានសម្ពោធ និងបាចទឹកព្រះពរដើម្បីសុំសេចក្តីសុខពីព្រះជាម្ចាស់កាលពីថ្ងៃទី៧ ធ្នូ ឆ្នាំ២០០៨។ អគារនេះគឺជាមណ្ឌលមនុស្សចាស់ជរាដែលមានទីតាំងនៅភូមិអណ្តូងច្រោះ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

មណ្ឌលនេះ គឺជាគម្រោងមួយរបស់ព្រះសហគមន៍កាតូលិកកំពង់ចាម និងដោយមានការចូលរួមយ៉ាងសកម្មអំពីសំណាក់យុវជនយុវនារី នៃក្រុមសន្តវ៉ាំងសង់ដឺប៉ូល ក្នុងតំបន់នេះ។ តាមសេចក្តីរាយការណ៍របស់លោកផាន់ បូរ៉ា នាយកគ្រប់គ្រងមណ្ឌលនេះនិយាយថា ការសាងសង់មណ្ឌលទទួលមនុស្សចាស់ជរាមិនមានទីពឹងនេះ ធ្វើឡើងក្នុងគោលបំណងតែមួយគត់ដើម្បីផ្តល់ឱ្យពួកគាត់ មានទីពំនាក់នៅក្នុងកាលៈទេសៈចុងក្រោយ នៃជីវិតរបស់ខ្លួន។ លោកផាន់ បូរ៉ា ក៏បញ្ជាក់ថា : "មណ្ឌលទទួលតែមនុស្សចាស់ដែលមិនមានទីពឹងពិតប្រាកដ និងក្រីក្របំផុតដោយគ្មានប្រកាន់សាសនាអ្វីឡើយ"។

ថវិកាសរុបក្នុងការសាងសង់មណ្ឌល អស់ប្រមាណ ៩០០០ដុល្លាអាមេរិក ដែលនេះជាអំណោយរបស់គ្រីស្តបរិស័ទនានាទាំងក្នុង និងក្រៅប្រទេស។ ប៉ុន្តែមណ្ឌលក៏នៅខ្វះខាតអគារផ្សេងៗទៀត ដូចជាផ្ទះបាយ និងកន្លែងសម្រាប់ហូបបាយជាដើម។



Photo : L. Sovanna

ក្រុមយុវនារីវ៉ាំងសង់ ឌឺ ប៉ូល នៅកំពង់ចាម ចែកបង្អែមដែលដែលការបង្ហាញអំពីការយកចិត្តទុកដាក់ចំពោះជនចាស់ជរា

## ដំណើរទស្សនកិច្ចដើម្បីកិច្ចសហប្រតិបត្តិការល្អ



Photo : L. Sovanna

គណៈប្រតិភូ ១ក្រុម នៃក្រសួងធម្មការ និងសាសនា ដឹកនាំដោយឯកឧត្តមផ្លោក ផនជារដ្ឋលេខាធិការ បានអញ្ជើញធ្វើទស្សនកិច្ច នៅព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាកាលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ កន្លងទៅនេះ។

ក្នុងកិច្ចសន្ទនាជាមួយគ្នា លោកអេមីល ដេតម្ប ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក៏បានថ្លែងអំណរគុណ ដល់រាជរដ្ឋាភិបាល ដែលផ្តល់សិទ្ធិសេរីភាព ក្នុងការផ្សព្វផ្សាយដំណឹងល្អនេះ នៅប្រទេសកម្ពុជា។ លោកសង្កត់ធ្ងន់ថា : "ព្រះសហគមន៍កាតូលិកមិនមែនជាអ្នកប្រឆាំងនឹងរដ្ឋាភិបាលទេ តែជាអ្នករួមជាមួយរដ្ឋាភិបាលដើម្បីជួយប្រជាជននិងសង្គម"។ រីឯឯកឧត្តមផ្លោក ផន ក៏បានមានប្រសាសន៍ សូមឱ្យមាននូវការគោរពគ្នាទៅវិញទៅមករវាងសាសនាទាំងពីរ ដូចជាព្រះយេស៊ូមានព្រះបន្ទូលថា : "ចូរស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង"។ ឯកឧត្តមក៏សូមឱ្យព្រះសហគមន៍កាតូលិករៀបចំសំណុំឯកសារច្បាប់ និងបញ្ជាក់ប្រវត្តិរបស់ទីកន្លែងនីមួយៗឱ្យបានច្បាស់សាល់ផងដែរ ដែលនេះមិនមែនតែព្រះសហគមន៍កាតូលិកទេ ដែលត្រូវធ្វើនោះគឺគ្រប់សាសនាទាំងអស់ត្រូវបំពេញដូចគ្នា។

**លី សុវណ្ណា**

## គ្រួសារ "ពន្លឺមិត្តភាព" នៅកម្ពុជាជួយកម្មករ



Photo : FCAC

គ្រួសារ"ពន្លឺមិត្តភាព" មានកំណើតនៅបារាំង នៅឆ្នាំ១៩៥០ និងមកដល់ ប្រទេសកម្ពុជាលើកទី១ នៅឆ្នាំ១៩៦៨ និងលើកទីពីរ គឺក្រោយសម័យសង្គ្រាមនៅឆ្នាំ ១៩៩៩។

គ្រួសារ"ពន្លឺមិត្តភាព"នៅកម្ពុជា ជាសមាគមមួយដែលមានគោលដៅលើកស្ទួយគាំទ្រយុវនារីយុវស្ត្រី ដែលជាកម្មការិនីរោងចក្រកាត់ដេរ។ បច្ចុប្បន្ននេះ គ្រួសារ បានទទួលនារីពីអាយុ ១៥ ដល់ ៤០ឆ្នាំ ប្រមាណ ១៥០នាក់ នៅផ្ទះមួយនៅរាជធានីភ្នំពេញ។ គ្រួសារ"ពន្លឺមិត្តភាព" គឺតែងព្យាយាមឆ្លើយតបចំពោះតម្រូវរបស់កម្មការិនីទាំងកាយ ទាំងចិត្ត ទាំងស្មារតី ដោយឱ្យពួកគាត់មកទទួលទានបាយនៅផ្ទះគ្រួសារ"ពន្លឺមិត្តភាព"។ ដូច្នេះគាត់អាចយកពេលវេលារិះគិតរួមជាមួយគ្នាអំពីជីវិតជាកម្មការិនី និងអំពីតម្លៃជីវិតជាស្ត្រី រៀនអាន និងសរសេរ រៀនធ្វើម្ហូបអាហារ រៀនផ្នែកអនាម័យ និងទទួលការតាមដានសុខភាពរបស់ខ្លួន...។

**នីកុល**

## ប្រជុំអំពីកសិកម្មលើកដំបូងក្នុងព្រះសហគមន៍កាតូលិក

កាលថ្ងៃទី៥ ធ្នូ ឆ្នាំ២០០៨ នៅព្រះសហគមន៍សន្តយ៉ូសែប ភ្នំពេញ មានការជួបប្រជុំគ្នាលើកទី១ រវាងអ្នកទទួលខុសត្រូវខាងផ្នែកកសិកម្មនៅតាមព្រះសហគមន៍កាតូលិក ប្រចាំមណ្ឌលមួយចំនួន ដូចជា កំពង់ចាម ពោធិ៍សាត់ កំពត តាកែវ និងបាត់ដំបង ជាមួយលោកអង់ទ័ន លីយ៉ែក អ្នកសម្របសម្រួលកសិកម្មនៅឯសាលាសន្តហ្វ្រង់ស្វ័រ និងសហការី ដែលជាអ្នកដឹកនាំការប្រជុំ។ សមាជិកចូលរួមមាន ១៥នាក់។

ជំនួបនេះជាការជជែកគ្នាអំពីកសិកម្មតាមព្រះសហគមន៍នីមួយៗ។ អ្នកទទួលខុសត្រូវម្នាក់ៗត្រូវរៀបរាប់អំពីសកម្មភាពដែលគេបានធ្វើជាមួយគោលបំណងនៃសកម្មភាពទាំងនោះ។

និយាយរួមគោលបំណងសំខាន់ នៃអង្គប្រជុំ គឺដើម្បីចែករំលែកនូវគំនិតចំណេះដឹង និងបច្ចេកទេសក្នុងការដាំដុះរវាងគ្នា និងគ្នា។

**ផាត សំភី**



Photo : P. Samphy



ព័ត៌មានព្រះសហគមន៍កាតូលិក

# កិច្ចសន្ទនាអន្តរសាសនា នាំមកនូវភាពសុខដុមរមនា

**លី សុវណ្ណា**

ព្រះសហគមន៍កាតូលិក នៅខេត្តកំពត បានរៀបចំការជួបជុំជាលក្ខណៈអន្តរសាសនា ថ្នាក់ខេត្ត ដើម្បីលើកកម្ពស់កិច្ចសន្ទនារវាងសាសនា និងសាសនាឱ្យបានទូលំទូលាយដើម្បីរស់នៅរួមគ្នាប្រកបដោយភាពសុខដុមរមនាកាលពីថ្ងៃទី២១ខែធ្នូ ឆ្នាំ២០០៨នេះ។ គណៈប្រតិភូចូលរួមមាន ព្រះគ្រូគៀត ចន្ទធុជ ព្រះអនុគណ ទីក្រុងព្រះសីហនុ និងជាទីប្រឹក្សាសម្តេចអគ្គព្រះសង្ឃរាជធិបតីទេព វង្ស លោកយី ធន់អគ្គលេខាធិការអន្តរសាសនានៅកម្ពុជា លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍ កាតូលិកភូមិភាគភ្នំពេញ លោកគ្រូគង្វាយគណៈនិកាយប្រូ-តេស្តង់ និងហាកីមឥស្លាមខេត្ត និងស្រុកកំពត។

មុនកិច្ចចាប់ផ្តើមគណៈប្រតិភូបានអញ្ជើញទៅចែកអំណោយដល់ទណ្ឌិត និងពិរុទ្ធជនសរុបចំនួន ២៧១នាក់ ដែលក្នុងនោះ មានស្ត្រី ១៩នាក់ និងអនិតិជនចំនួន ២០នាក់ នៅពន្ធនាគារខេត្តកំពត។

លោកយី ធន់ បានមានប្រសាសន៍ទៅកាន់ទណ្ឌិតថា មនុស្សទាំងអស់កើតមកមានទុក្ខ មិនថាតែបងប្អូននៅទីនេះទេ។ ដូច្នេះសូមបងប្អូនខិតខំលត់ដំខ្លួន ពុំយូរទេបងប្អូននឹងមានសេរីភាពឡើងវិញ។

បន្ទាប់មកគណៈប្រតិភូបានប្រសិទ្ធពរតាមរបៀបសាសនានីមួយៗដល់ក្រុមទណ្ឌិតនិងចែកអំណោយដល់ពួកគេ ដែលរៀបចំ ដោយលោកបូជាចារ្យអ៊ុនសុន នៃព្រះសហគមន៍កំពត និងមានការចូលរួមពីព្រះគ្រូគៀត ចន្ទធុជ ចំនួន១ ០០០ ០០០រៀល និងអ្នកស្រីសាឡៃសង្ឃឹម ១០០ ដុល្លារអាមេរិក។

បន្ទាប់មក គណៈប្រតិភូក៏បានត្រលប់ទៅជួបជុំនៅព្រះសហគមន៍កាតូលិកកំពតវិញដើម្បីធ្វើការបើកប្រជុំអន្តរសាសនា លោកបូជាចារ្យអ៊ុន សុន ក៏មានប្រសាសន៍ថា : "ថ្ងៃនេះគឺជាពេលល្អប្រសើរណាស់ដែលគ្រប់សាសនាទាំងអស់បានជួបមុខគ្នាដើម្បីធ្វើសកម្មភាពរួមគ្នា និងគាំទ្រគ្នាទៅវិញទៅមក"។

លោកយី ធន់ បានយល់ស្របដូច្នេះ និងបន្តថា គ្រប់សាសនាទាំងអស់សុទ្ធមានសេចក្តីមេត្តា និងសេចក្តីស្រឡាញ់។ នៅថ្ងៃនេះ យើងក៏បានធ្វើបុណ្យរួមគ្នាចំពោះអ្នកដែលត្រូវការ និងស្រេកឃ្លានពិតប្រាកដដែលនាំឱ្យយើងសប្បាយចិត្ត។

ព្រះគ្រូគៀត ចន្ទធុជ មានសង្ឃដីការដែរថា ការធ្វើទានសម្រាប់អ្នកក្រក្រី គឺមានសារៈសំខាន់ ពិសេសចំពោះទណ្ឌិត ដែលយើងបានធ្វើអំបាញ់មិញនេះ។ ទណ្ឌិតទាំងអស់សុទ្ធតែស្រេកឃ្លាន ទោះបីជាបានប្រព្រឹត្តខុស តែពួកគេសុទ្ធតែស្តាយក្រោយ។ដូច្នេះការផ្តើមគំនិតធ្វើកុសល ដោយលោកអ៊ុនសុន មានអត្ថន័យយ៉ាងជ្រាលជ្រៅណាស់។

ចំណែកលោកអេមីលមានស្រាសន៍ថា : "ការដែលយើងទាំងអស់គ្នាមានយោបល់ និងគំនិតតែមួយ គឺមិនមានទេ"។ តែទោះបីយើងមានគំនិតយោបល់ច្រើន ក៏យើងត្រូវតែ ចេះគោរពគ្នា។ គ្រីស្តបរិស័ទក៏ត្រូវគោរពអ្នកដទៃ ពិសេសជំនឿរបស់គេ ដើម្បីជាប្រយោជន៍ និងសន្តិភាពក្នុងសង្គមជាតិ។

## ប្រវត្តិក្រុមប្រឹក្សាអន្តរសាសនា

ក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា ដែលបានបង្កើតនៅថ្ងៃទី១០ តុលា ឆ្នាំ២០០២ និងមានមេដឹកនាំព្រះពុទ្ធសាសនា អ៊ិស្លាមសាសនា គ្រីស្តសាសនាទាំងពីរនិកាយ គឺកាតូលិក និងប្រូតេស្តង់ និងសហគមន៍សាសនាផ្សេងៗទៀត នៅព្រះរាជាណាចក្រកម្ពុជា បានសម្រេចចុះហត្ថលេខារួមគ្នាព្រមព្រៀងបង្កើតឡើងដើម្បីភាពសុខដុមរមនា និងសន្តិភាព នៅក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជាសាកលលោកទាំងមូល។ ក្រុមប្រឹក្សានេះជាសមាជិកក្រុមប្រឹក្សាអន្តសាសនាសកលលោកដែលមានការិយាល័យនៅក្រុងញូយ៉កផងដែរ។



Photo : L. Sovanna

# សិក្ខាសាលានៃការផ្លាស់ប្ដូរបទពិសោធន៍របស់យុវជន

**អាតន**



សកម្មភាពចែកជាក្រុមពិភាក្សាគ្នាក្នុងសិក្ខាសាលា

Photos : Sokhorn

កាលថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៨ អង្គការអភិវឌ្ឍន៍ធនធានយុវជន រៀបចំសិក្ខាសាលាមួយលើប្រធានបទ"ការផ្លាស់ប្ដូរបទពិសោធន៍របស់យុវជន" ដែលប្រព្រឹត្តទៅនៅការិយាល័យរបស់ខ្លួន ដែលស្ថិតក្នុងខណ្ឌ ទួលគោក រាជធានី ភ្នំពេញ។ សិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលានេះ មានចំនួន ៩០នាក់ ដែលក្នុងនោះ មានអាណាព្យាបាលនិស្សិត និស្សិត និងតំណាងអាជ្ញាធរមូលដ្ឋាន។

ជាកិច្ចចាប់ផ្ដើមអង្គសិក្ខាសាលា លោកជាង សុខា នាយកប្រតិបត្តិនៃអង្គការអភិវឌ្ឍន៍ធនធានយុវជន ក៏មានប្រសាសន៍ថា នេះគឺជាលើកទីមួយដែលអង្គការអភិវឌ្ឍន៍ធនធានយុវជន បានរៀបចំឡើងដោយមានការអញ្ជើញចូលរួម ពីសំណាក់អាណាព្យាបាលនិស្សិត និស្សិត និងអាជ្ញាធរ ដែលពីមុនៗមក មិនធ្លាប់មាន។ លោកសង្កត់ធ្ងន់ទៅលើគោលបំណងនៃសិក្ខាសាលានេះថា ដោយមើលឃើញថាក្នុងចំនួនប្រជាជនកម្ពុជា ជាង ១៤លាននាក់ មានយុវជនមានដល់ទៅ ៧០% ដែលវាជាចំនុចសំខាន់មួយត្រូវការបណ្ដុះបណ្ដាលពួកគេឱ្យមានគុណភាពដើម្បីឆ្លើយតប ទៅនឹងតម្រូវការនៅក្នុងគ្រួសារ ក៏ដូចជាសង្គមជាតិ។ ដូច្នេះហើយដើម្បីបានសម្រេចគោលដៅនេះ សិក្ខាសាលាប្រហែលជាឱកាសមួយដែលយុវជនអាចសិក្សាពីគ្នាទៅវិញទៅមក ដោយឆ្លុះបញ្ចាំងទៅលើតថភាពជាក់ស្ដែង ដែលមាននៅក្នុងសង្គមរបស់កម្ពុជា។

កញ្ញាទ្រី សុខជួង ជានិស្សិតសង្គមវិទ្យាឆ្នាំទី២ នៅឯសកលវិទ្យាល័យភូមិន្ទភ្នំពេញ និយាយថា កញ្ញាមានការផ្លាស់ប្ដូរការគិតរបស់ខ្លួន ចំពោះអ្នកដទៃរហូតដល់៥០ ឬ៦០% គឺចាប់ពីពេលបានចូលរៀនវគ្គបណ្ដុះបណ្ដាលផ្នែកអភិវឌ្ឍន៍ខ្លួនឯងនៅអង្គការអភិវឌ្ឍន៍ធនធានយុវជន។ កញ្ញាបន្តថា កាលពីមុនកញ្ញាវាយតម្លៃអ្នកដទៃតាមសំបកខាងក្រៅ។ តែឥឡូវនេះមិនមែនទេ កញ្ញាក៏មើលទៅលើបុព្វហេតុហេតុផល និងបញ្ហាពួកគេផងដែរ។

សូមបញ្ជាក់ដែរថា អង្គការអភិវឌ្ឍន៍ធនធានយុវជននេះបង្កើតឡើងនៅក្នុងឆ្នាំ១៩៩២។ គោលដៅរបស់អង្គការ គឺបណ្ដុះមនសិការសង្គមដល់និស្សិតដើម្បីឱ្យពួកគេចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍សង្គម កសាងសន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍន៍មួយដែលប្រកបដោយនិរន្តរភាព។

## ញៀន វិចិត្រ : "ខ្ញុំមានការផ្លាស់ប្ដូរទាំងស្រុង" ដោយបានរៀនវគ្គនេះ

លោកញៀន វិចិត្រ និស្សិតឆ្នាំទី២ នៃមហាវិទ្យាល័យធនធានមនុស្ស ជំនាញភាសាអង់គ្លេស។

លោកបញ្ចេញយោបល់ខ្លួនថា បន្ទាប់ពីបានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលនៃអង្គការអភិវឌ្ឍន៍យុវជន បានចំនួនប្រាំវគ្គ ក្នុងនោះ មានវគ្គ ការអភិវឌ្ឍន៍ខ្លួនឯង ភាពជាអ្នកដឹកនាំ អំពើអហិង្សាសកម្ម ការស្វែងរកការងារធ្វើ និងលិទ្ធិប្រជាធិបតេយ្យ លោកមានការពេញចិត្តវគ្គការអភិវឌ្ឍន៍ខ្លួនឯងជាងគេ ពីព្រោះវាផ្ដោតជាសំខាន់ទៅ លើការគិតពិចារណា ការវិភាគ និងស្គាល់ខ្លួនឯង។

លោកញៀន វិចិត្រ និយាយថា : "ខ្ញុំមានការផ្លាស់ប្ដូរទាំងស្រុង" ដោយបានរៀនវគ្គនេះ គឺផ្លាស់ប្ដូរពីមនុស្សម្នាក់ទៅម្នាក់ទៀត គឺដោយលោកចេះបើកចិត្តឱ្យទូលាយដើម្បីទទួលយកគំនិតរបស់ដទៃ មកធ្វើជាបទពិសោធន៍ និងចំណេះដឹងថ្មីៗ សម្រាប់ខ្លួនឯង ព្រមទាំងចេះមានទំនាក់ទំនងជាមួយអ្នកដទៃ និងចេះស្ដាប់ ដូចជាការនិយាយ និងកាយវិការ ក្នុងការឆ្លើយតបទៅរកអ្នកទាំងនោះដោយគោរព"។



លោកបន្តទៀតថា វគ្គនៃការអភិវឌ្ឍន៍ខ្លួនឯងនេះ បានជួយដល់ការសិក្សាលោកនៅឯមហាវិទ្យាល័យផងដែរដោយហេតុថាក្នុងនាមជានិស្សិតម្នាក់ ដែលកំពុងចំណាយពេលច្រើនក្នុងការសិក្សា និងស្រាវជ្រាវនោះ ប្រសិនបើយើងមិនស្គាល់ពីភារកិច្ច និងតួនាទីរបស់ខ្លួន នេះជាទង្វើដែលប្រៀបដូចបិទផ្លូវចំពោះខ្លួនក្នុងការកសាងអនាគតអ៊ីចឹងដែរ។

លោកបង្ហាញអំពីគម្រោងអនាគតថា លោកចង់ធ្វើការងារជាមួយនិងអង្គការអភិវឌ្ឍន៍ធនធានយុវជនផ្នែកសម្របសម្រួលយុវជន ព្រោះថា ប្រទេសជាតិ គឺពិតជាត្រូវការយុវជនដែលមានសមត្ថភាពដើម្បីបន្តវេននៅពេលខាងមុខ។







Photo : S. Philong

ការចំណាយពេលវេលាច្រើនដើរកំសាន្តធ្វើឱ្យប៉ះពាល់ការសិក្សា

# ភាពភ្លើតភ្លើនកំពុងជំរុញឱ្យសិស្សគេចសាលា

**ខាន់ ភីរម្យ**

ភាពភ្លើតភ្លើន និងសម្ភារៈនិយម កំពុងធ្វើឱ្យយុវជន និងយុវនារី ដែលស្ថិតក្នុងវ័យសិក្សាមួយចំនួនគិតខុស និងគេចសាលា។ នេះបើតាមការអះអាងរបស់អ្នកមានតួនាទីអប់រំនៅសាលាចំណេះទូទៅ។

ពីមួយថ្ងៃ ទៅមួយថ្ងៃ នៅតាមកន្លែងកំសាន្តនានា ដូចជានៅរមណីយដ្ឋានតាមផ្លូវជាតិលេខ៦អា ក្លឹបកំសាន្តនានានៅក្នុងទីក្រុងភ្នំពេញ គេសង្កេតឃើញមានយុវជន និងយុវនារីក្មេងៗដែលភាគច្រើនមានអាយុពី១៥ ទៅ២០ឆ្នាំ ដែលជាវ័យសិស្សា បាននាំគ្នាពាក់ពព្ធូនដើរកំសាន្តជាមួយនឹងសម្ភារៈ ដូចជាម៉ូតូ ទូរស័ព្ទដៃទំនើបៗ ដោយខ្លះ ស្លៀកពាក់ស្អាតបាត។ ខ្លះស្លៀកខ្លីខើចតាមរបៀប ជាយុវវ័យទាន់សម័យ ដែលគេនិយមហៅ នៅក្នុងភាសាសាមញ្ញថាស៊ិចស៊ី។ អ្នកខ្លះទៀតបិតនៅក្នុងសម្លៀកបំពាក់ជាសិស្សសាលាតែម្ដង។ ពួកគេដើរលេងជាពិសេស នៅ ថ្ងៃសុក្រ ឬថ្ងៃសៅរ៍ ដែលជាថ្ងៃរៀន។

ស្ត្រីនៅវ័យកណ្ដាល ១រូប ដែលបានចូលចាក់សាំងនៅស្ថានីយប្រេងសាំងកាល់តិច បឹងត្របែក មានប្រសាសន៍ថា ជារៀងរាល់ថ្ងៃចុងសប្ដាហ៍ ពេលអ្នកស្រីចូលចាក់សាំងនៅស្ថានីយនេះ អ្នកស្រីក៏តែងតែឃើញក្មេងៗពពាក់ពពូនជុំគ្នា ជាមួយនឹងម៉ូតូថ្មីៗ។ អ្នកស្រីអះអាងថា ពួកគេខ្លះស្លៀកសម្លៀកបំពាក់ដើរលេងស្រាប់ អ្នកខ្លះស្លៀកជាសិស្ស។ តែអ្វីដែលអ្នកស្រីប្រាប់នោះ គឺមួយចំនួនដែលអ្នកស្រីឃើញបានមកផ្លាស់ខោអាវសិស្សចេញ។ អ្នកស្រីបញ្ជាក់ថា : "ខ្ញុំមិនដឹងថា ពួកគេគេចសាលា ឬអត់ទេ តែខ្ញុំឃើញពួកគេជុំៗនៅទីនេះមែន"។

យុវជនមួយរូបដែលអះអាងថា មានវ័យត្រឹម ១៦ ឆ្នាំ ជិះម៉ូតូម៉ាកអ៊ែប្លែក ដែលបង្ហាញអត្តសញ្ញាណរបស់គេថា ជាសិស្សថ្នាក់ទី១០ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និយាយថា : "ខ្ញុំនៅចាំគ្នាដើរលេង។ ខ្ញុំមិនគេចសាលាទេ។ នេះគឺម៉ោងលីប"។

ពាក់ព័ន្ធជាមួយបញ្ហានេះ លោកសេង លីម នាយកសាលាវិទ្យាល័យស៊ីសុវត្ថិ មានប្រសាសន៍ថា សិស្សនៅវិទ្យាល័យ ដែលលោកគ្រប់គ្រង ពិតជាមានខ្លះគេចសាលាមែន ប៉ុន្តែមិនច្រើនទេ។ លោកបញ្ជាក់ទៀតថា : "យើងមានសិស្សទាំងអស់ចំនួន ៦៧០៧ នាក់។ អ្នកដែលគេចគឺមានតែពីរបីនាក់ប៉ុណ្ណោះ"។ លោកថាសិស្សដែលគេចសាលាជាមុខដដែលៗ។

នៅក្រុងព្រះសីហនុឯណោះវិញ ក៏មានសេចក្ដីរាយការណ៍ថា សិស្សាគេចសាលាក៏មានច្រើនដែរ។ បើទោះបី ទីនោះគឺជាទីក្រុងឆ្នេរសមុទ្រ ដ៏ស្រស់ស្អាតមួយតូច និងមានប្រជាពលរដ្ឋតិចក៏ដោយ។

លោកខូវ វុទ្ធី នាយករងវិទ្យាល័យក្រុងព្រះសីហនុ មានប្រសាសន៍ថា សិស្សដែលគេចសាលា ត្រូវបានសាលារកឃើញជាហូរហែដែរ។ ក្នុងចំណោមសិស្សប្រមាណ ២២០០នាក់ជាង សិស្សដែលគេចសាលាមានប្រមាណមិនដល់ ១០%ទេ"។ ពួកគេទាំងអស់នោះ ភាគច្រើនជាអ្នកដែលមានជីវភាពធូធារ តែភ្លើតភ្លើន។ លោកប្រាប់ដែរថា ដើម្បីជួយកែតម្រូវពួកគេ សាលាក៏តែងជូនដំណឹងទៅអាណាព្យាបាលរបស់ពួកគេជាបន្តបន្ទាប់។ ប៉ុន្តែករណីខ្លះ គឺពិបាកដោយសារតែសាលាខ្វះមធ្យោបាយ ក្នុងការទំនាក់ទំនង។ មូលហេតុម្យ៉ាង គឺយុវសិស្ស ដែលខិលខូចតែងតែព្យាយាមផ្ដល់ព័ត៌មានមិនពិតដល់សាលា។ ចំពោះពួកគេ យើងអាចគ្រប់គ្រងបានតែក្នុងសាលា និងរាយការណ៍ទៅអាណាព្យាបាល។ ប៉ុន្តែបើត្រង់ថា ពួកគេគេចទៅធ្វើអ្វីនោះ សាលាពុំអាចដឹងទេ។ លោកក៏សង្កត់ធ្ងន់ថា : "យើងមានតួនាទីអប់រំ និងតាមដានគេតែនៅក្នុងសាលា។ នៅក្រៅសាលា គឺហួសភារកិច្ច។ សាលាមានតួនាទីត្រឹមតែអប់រំ និងជូនដំណឹងទៅអាណាព្យាបាលតែប៉ុណ្ណោះ"។

January-2009.qxd 12/28/2008 4:21 PM Page 10

## បទយកការណ៍

# ៧ មករា ២០០៩ ខួប ៣០ឆ្នាំ បញ្ចប់របបប្រល័យពូជសាសន៍

ខាន់ ភិរម្យ

"ជយោ! ៧ មករា"ជាសម្រែកអបអរ ដែលប្រជាពលរដ្ឋកម្ពុជាបន្លឺតាំងតែពីឆ្នាំ១៩៧៩ ហើយរហូតមកដល់ពេលនេះ គឺមានរយៈពេល ៣០ឆ្នាំហើយ ។ ប្រជាជនកម្ពុជា នៅតែអះអាងថា ពួកគាត់នៅតែស្រែកសំឡេងជ័យឃោស នេះដដែល ។

លោកស វុទ្ធី ជានាយកស្ថានីយវិទ្យុ FM ៩១ ខេត្តបាត់ដំបង មានប្រសាសន៍ថា ក្នុងនាមជាខ្មែរដែលនៅរស់សេសសល់ពីជំនាន់ប៉ុលពត ថ្ងៃ៧មករា នៅតែជាថ្ងៃចង់ចាំជានិច្ចសម្រាប់ជីវិតរបស់គាត់ ។

លោកបញ្ជាក់ដែរថា: "សម្រាប់អ្នកដែលហែលឆ្លងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃនោះ ថ្ងៃ៧មករា គឺជាថ្ងៃកំណើតទីពីររបស់ពួកគេ" ។ លោកក៏បន្តឱ្យដឹងដែរថា លោកអាចមានវ័យ ចាំបានសព្វយ៉ាងសម្រាប់អ្វីដែលបានកើតឡើងនៅក្នុង សម័យប៉ុលពត និងអ្វីដែលកើតមានឡើង នៅដើមដំបូង ក្រោយពីរបបនេះដួលរលំហើយនេះ ។ លោករៀបរាប់ដែរថា: "ខ្ញុំមានវ័យ១២ឆ្នាំពេលរបបប៉ុលពតចាប់ផ្តើម ។ ដល់បែកប៉ុលពត ខ្ញុំមានវ័យ ១៥ឆ្នាំ" ។ លោកបន្ថែមថា ជំនាន់ប៉ុលពត ជាពេលដែលខ្លោចផ្សារបំផុតចំពោះជីវិតមនុស្ស ព្រោះសូម្បីតែកុមារក៏ត្រូវបានគេចាប់បង្ខំឱ្យធ្វើការងារធ្ងន់ បែកពីគ្រួសារដែរ ។ ហើយអ្វីដែលសំខាន់ក្រៅអំពីការងារជាទម្ងន់ ប្រជាជនគ្មានសិទ្ធិអ្វីទាំងអស់ គឺសូម្បីតែជីវិត ក៏មិនមែនជារបស់ពួកគាត់ដែរ ។ ប៉ុន្តែក្រោយពេលដែលប៉ុលពតដួលរលំនៅ ថ្ងៃ៧ មករា ទៅ អ្វីៗក៏បានផ្លាស់ប្តូរជាបន្តបន្ទាប់ជាជំហានៗ ។ លោកបាននិយាយបន្តថា នៅក្រោយ ថ្ងៃ៧មករា អ្វីដែលយើងទទួលបានមុនគេ គឺសិទ្ធិជាមនុស្ស ត្រូវបានគេគោរពដូចជាបានទទួលទានឆ្អែត ពុំមានការចាប់បង្ខំឱ្យធ្វើការហួសកម្លាំង មាននូវសេរីភាព ការអប់រំ ការគោរពសិទ្ធិ និងការអនុវត្តជំនឿសាសនាដែលខ្លួនជឿ ។ ហើយអ្វីដែលសំខាន់ និងអាចមើលឃើញ ឱ្យច្បាស់លាស់ជាងគេនោះ គឺមានការអភិវឌ្ឍន៍នៅក្នុងប្រទេស ។

បើក្រឡេកក្រោយ ទៅមើលប្រវត្តិសាស្ត្រ ក្រោយពេល ដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង នៅក្នុងឆ្នាំ១៩៥៣ សន្ទុះនៃការរួបរួមជាតិ និងកសាងជាតិក៏បានស្ទុះឡើងយ៉ាងលឿន ។ ប៉ុន្តែជាអកុសល ចាប់ពីខែមីនា ឆ្នាំ១៩៧០ សង្គ្រាមស៊ីវិលមួយ បានកើតមានឡើងរហូតដល់ធ្វើឱ្យខ្សឿនសេដ្ឋកិច្ច មួយភាគធំក៏ត្រូវបានបំផ្លាញចោល ។ លុះដល់ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាបានទទួលសន្តិភាពបែបថ្មីមួយមែន ប៉ុន្តែសន្តិភាពនោះ មិនបាននាំមកនូវអ្វីដែលជាសមិទ្ធផលថ្មីទេ ប៉ុន្តែបែរជានាំមកនូវគ្រោះមហន្តរាយ និងវិនាសកម្មដល់ប្រទេស លើគ្រប់វិស័យ ហើយអ្វីដែលមិនអាចធ្វើឱ្យយើងនឹងធ្វើការពិពណ៌នាបាននោះ គឺមានការស្លាប់នៃប្រជាពលរដ្ឋស្លូតត្រង់ ដល់ចំនួន ១,៧លាននាក់ ។ ប៉ុន្តែទោះជាយ៉ាងណាវិនាសកម្មនេះ ក៏ត្រូវបានបញ្ចប់នៅក្នុងខែមករា ឆ្នាំ១៩៧៩ ។

ប្រទេសជាតិក៏មិនទាន់បានសុខក្សាន្តទេ ដោយត្រូវប្រឈមមុខនឹងសង្គ្រាមស៊ីវិល ជាថ្មីម្តងទៀត រវាងរដ្ឋាភិបាលទីក្រុងភ្នំពេញ ដែលគាំទ្រដោយកងទ័ពវៀតណាម ជាមួយកម្លាំងតស៊ូប្រដាប់អាវុធបីក្រុមផ្សេងទៀត នៅតាមជាយព្រំដែន ។ សង្គ្រាមនេះក៏បន្តរហូតដល់ ឆ្នាំ១៩៩៣ ទើបក្រុមជម្លោះប្រដាប់អាវុធទាំងអស់ បានសម្រេចមករួមរស់ ជាមួយគ្នាវិញ គឺលើកលែងក្រុមខ្មែរក្រហមដែលដឹកនាំដោយ ប៉ុលពតដែលមិនរួបរួម គឺរហូតដល់ឆ្នាំ១៩៩៨ទើបកម្ពុជាបានទទួលសន្តិភាពទាំងស្រុង ។


រយៈពេល ៣០ឆ្នាំ ពីទីក្រុងខ្មោច មកភាពរីកចម្រើនគួរឱ្យកត់សម្គាល់

Photo : S. Philong

### ប្រទេសកម្ពុជាចាប់តាំងពីសង្គ្រាមស៊ីវិលរហូតដល់បញ្ចប់

ឆ្នាំ១៩៥៣ *ព្រះរាជាណាចក្រកម្ពុជា* ដឹកនាំដោយសម្តេចនរោត្តម សីហនុ។ ឆ្នាំ១៩៧០ *សាធារណរដ្ឋខ្មែរ* ដឹកនាំដោយលោកសេនាប្រមុខលន់ នល់។ ឆ្នាំ១៩៧៥ *កម្ពុជាប្រជាធិបតេយ្យ* លោកប៉ុលពតដឹកនាំ។ ពីឆ្នាំ១៩៧៩ *សាធារណរដ្ឋប្រជាមានិតកម្ពុជា* លោកប៉ែន សុវណ្ណ លោកចាន់ ស៊ី និងលោកហ៊ុន សែន ដឹកនាំ។ ឆ្នាំ១៩៨៩ *រដ្ឋកម្ពុជា* ដឹកនាំដោយលោកហ៊ុន សែន។ ឆ្នាំ១៩៩១ *កម្ពុជា* ក្រោមការត្រួតពិនិត្យដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា និងឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់។ ឆ្នាំ១៩៩៣ *ព្រះរាជាណាចក្រកម្ពុជា* សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេចហ៊ុន សែនដឹកនាំ។ ឆ្នាំ១៩៩៨ *ព្រះរាជាណាចក្រកម្ពុជា* សម្តេចហ៊ុន សែនដឹកនាំ។ ឆ្នាំ២០០៣ *ព្រះរាជាណាចក្រកម្ពុជា* ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។

ចំណែកឯលោកស្រីជា វណ្ណាត អតីតប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម មានប្រសាសន៍ថា: "ថ្ងៃ៧ មករា គឺជាចំណុចរបត់ប្រវត្តិសាស្ត្ររបស់ពង្សាវតាខ្មែរ" ។ លោកស្រីបន្តដែរថា ចំពោះការយល់ឃើញរបស់ពលរដ្ឋខ្មែរចំពោះ ៧ មករានេះ គឺមានពីរ បើនិយាយអំពីប្រជាពលរដ្ឋខ្មែរមួយចំនួន ដែលលោករស់នៅបរទេសនោះ លោកមើលឃើញថា វាគឺជាថ្ងៃមួយដែលប្រទេសត្រូវបរទេសលុកលុយ ។ តាមរយៈទូរស័ព្ទ លោកស្រីរៀបរាប់លំអិតថា: "នេះជាការពិត ព្រោះចាប់ពីថ្ងៃ៧ មករា គេឃើញកងទ័ពវៀតណាមមានវត្តមាន គឺរហូតដល់ ឆ្នាំ១៩៨៩" ។ ទោះជាយ៉ាងនេះក្តី លោកស្រីនិយាយតាមរបៀបមួយទៀតថា ប៉ុន្តែពលរដ្ឋខ្មែរភាគច្រើន ដែលបានរស់នៅ និងហែលឆ្លងរបបប៉ុលពតវិញនោះ លោកប្រាកដជាយល់ថា វាគឺជាថ្ងៃកំណើតទីពីរ ឬថ្ងៃរស់ឡើងវិញរបស់លោក ។ លោកស្រីបញ្ជាក់ថា ទោះជាយ៉ាងនេះក្តី ក្នុងនាមជាពលរដ្ឋខ្មែរដូចគ្នា សូមកុំយកទស្សនៈទាំងពីរនេះ មកធ្វើឱ្យយើង បែកបាក់គ្នា ។ លោកស្រីសង្កត់ធ្ងន់ដែរថា: "ការបែកបាក់ គឺមិនចំណេញដាច់ខាតចំពោះជាតិខ្មែរ" ។

សម្រាប់លោកបណ្ឌិតរស់ ចន្ទ្រាបុត្រ ជាអនុប្រធានរាជបណ្ឌិតសភាកម្ពុជា មានប្រសាសន៍ថា ទោះអ្នកណាគេថាយ៉ាងណាក៏ដោយ តែអ្វីដែលប្រជាពលរដ្ឋកម្ពុជាគួរចាំនោះគឺថា ថ្ងៃ៧មករាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃការកែប្រែរបបមួយរបស់ប្រជាពលរដ្ឋកម្ពុជា កាលពី៣០ឆ្នាំមុន ។ លោកក៏បញ្ជាក់ថា: "មុនថ្ងៃ៧ មករា ១៩៧៩ ជារបបវាលពិឃាត ប៉ុន្តែក្រោយ ៧ មករា ១៩៧៩ វាគឺជាថ្ងៃនៃការចាកផុតរបស់ពួកគេ" ។

ពិតណាស់! ចាប់តាំងពីថ្ងៃ៧ មករា ឆ្នាំ១៩៧៩មកដល់ពេលនេះ មានសមិទ្ធផលថ្មីៗជាច្រើន ត្រូវបានកសាងឡើងជាបន្តបន្ទាប់ ។ ហើយសមិទ្ធផលទាំងនេះ គឺងាយស្រួលមើលបំផុត ។

លោកស្រី ជា វណ្ណាត មានប្រសាសន៍ទៀតថា: "អ្វីដែលសម័យប៉ុលពតអត់មាន ហើយមកដល់ពេលនេះមាន វាជាសមិទ្ធផល ថ្ងៃ៧ មករា ហើយ" ។

ចំណែកលោកបណ្ឌិតរស់ ចន្ទ្រាបុត្រ អះអាងថា បើនិយាយអំពីសមិទ្ធផលរបស់ថ្ងៃ៧មករា មានច្រើនណាស់ យើងមិនអាចរៀបរាប់បានទេ ។ តែអ្វីដែលសំខាន់ ហើយងាយនិយាយជាងគេ គឺសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ រួមនិងសេដ្ឋកិច្ចរបស់ប្រទេសដែលកំពុងតែដំណើរការដូចសព្វថ្ងៃ ។ លោកបណ្ឌិតបន្តថា សន្តិភាពនៅប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ វាក៏ជាសមិទ្ធផលអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃថ្ងៃ៧ មករា នេះផងដែរ ។

អំពីសមិទ្ធផលនេះ លោកវុទ្ធី រៀបរាប់ថា: "ខ្ញុំរាប់សមិទ្ធផលពីថ្ងៃ៧ មករា គឺអត់អស់ទេ" ។ លោកប្រាប់ថា សមិទ្ធផល គឺមានតាំងពីសាលារៀន មន្ទីរពេទ្យ វត្តអារាម ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងធារាសាស្ត្ររហូតដល់សេដ្ឋកិច្ចរីកចម្រើន-ល-។

ទន្ទឹមជាមួយនឹងសមិទ្ធផល បញ្ហាសង្គមថ្មីៗក៏កំពុងតែកើតមាននៅប្រទេសកម្ពុជា នាពេលសព្វថ្ងៃនេះផងដែរ នោះគឺគម្លាតសង្គម និងបញ្ហាពុករលួយ ។ លោកស្រី វណ្ណាតបន្ថែមថា គម្លាតសង្គម និងបញ្ហាក្រីក្រជាដើមនេះ ត្រូវបានអ្នកសិក្សាស្រាវជ្រាវរកឃើញជាយូរឆ្នាំណាស់មកហើយ ។ ប៉ុន្តែវាហាក់ដូចជានៅតែមាននៅក្នុងសង្គមកម្ពុជាដដែល ។ លោកស្រីសំណូមពរថា: "រដ្ឋាភិបាលគួរតែប្រឹងប្រែង" ។

លោកបណ្ឌិត ចន្ទ្រាបុត្រ គាំទ្រថា មានបញ្ហាអសកម្មទាំងនេះ និងលើកឡើងថា ភាពក្រីក្របញ្ហាពុករលួយ និងបញ្ហាសង្គម ផ្សេងៗទៀត គឺពិតជាកើតមានឡើងមែន ។ ប៉ុន្តែលោកក៏រៀបរាប់ថា កាលពី ៣០ឆ្នាំមុន ធនធានរបស់ប្រទេសកម្ពុជា ស្ទើរទាំងស្រុងត្រូវបំផ្លាញចោល ។ ហើយសមិទ្ធផលថ្មីៗ នៅពេលនេះ មិនមែនជាការកែលំអទេ ។ ភាគច្រើន គឺកើតឡើងថ្មីតែម្តង ។ លោកបញ្ជាក់ថា : "ខ្ញុំទទួលស្គាល់អំពីចំណុចអវិជ្ជមាន ។ តែយើងមិនអាចដោះស្រាយក្នុងពេលតែ ៣០ឆ្នាំ នេះទេ" ។ លោកក៏បន្តទៀតថា រដ្ឋាភិបាលកំពុងព្យាយាម ដោះស្រាយជាជំហានៗចំពោះបញ្ហាអសកម្មទាំងនេះដែរ ។

ចាប់តាំងពីថ្ងៃទី៧ មករា ឆ្នាំ១៩៧៩មក ប្រជាពលរដ្ឋកម្ពុជាតែងតែរៀបចំពិធីអបអរ និងរំលឹកអនុស្សាវរីយ៍ជារៀងរាល់ឆ្នាំ ហើយតាមការគ្រោងទុក ថ្ងៃទី៧ មករា ឆ្នាំ២០០៩ ដែលនឹងមកដល់ចំថ្ងៃពុធ រដ្ឋាភិបាលកម្ពុជា គ្រោងនឹងរៀបចំពិធីអបអរ ដ៏ធំមួយដែលមិនដែលមាន ដើម្បីអបអរ ខួបទី៣០ឆ្នាំនៃព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ។

### សមិទ្ធផលត្រួសៗ ក្រោយ ៧ មករា ១៩៧៩

៣០ឆ្នាំ នៃដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដែលចាប់ផ្តើមតាំងពីបាតដៃទទេ បានទទួលកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦ ប្រទេសកម្ពុជាបានទទួលកំណើនជាមធ្យម ៩,៤% ក្នុងមួយឆ្នាំ ហើយកាលពីឆ្នាំ២០០៧ កន្លងទៅឡើងដល់ ៩,៨%។ រីឯប្រាក់ចំណូលវិញ គឺកើនឡើងពី ២៨៨ដុល្លារ ដល់៥៨៣ដុល្លារ សម្រាប់ម្នាក់ៗ ក្នុងមួយឆ្នាំ។ ហើយកាលពីពេលថ្មីៗនេះ សម្តេចហ៊ុន សែន បានអះអាងថា វាបានឡើងដល់ជាង ៦០០ដុល្លារ។ ចំណែកភាពក្រីក្រវិញ កាលពី១៦ឆ្នាំមុន មានរហូតដល់ ៤៥%។ វាបានធ្លាក់ចុះមកនៅត្រឹម ៣១% នៅឆ្នាំ២០០៧ ហើយគេអះអាងថា បញ្ហានេះនឹងធ្លាក់ចុះ១% រៀងរាល់ឆ្នាំ។ វិស័យវិនិយោគទុនបរទេសដែលកាលពី១៧ឆ្នាំកន្លងទៅ មានត្រឹមតែ៣លានដុល្លារ បានឡើងដល់៨,៩ពាន់លានដុល្លារ កាលពីខែសីហា ឆ្នាំ២០០៨។ ក្រៅពីនេះកម្ពុជាក៏ជាប្រទេសឈានមុខគេមួយខាងការនាំចេញសម្លៀកបំពាក់ ហើយក៏កំពុងតែត្រៀមរៀបចំខ្លួន ជាប្រទេសនាំចេញស្រូវ និងកសិកម្មមួយចំនួនទៀត។

January-2009.qxd 12/28/2008 4:21 PM Page 12

## កសិកម្ម

# បច្ចេកទេសដាំប៉េងប៉ោះទទួលផលល្អ

**ផាត សំភី**

លោកគ្រុយ លឹមហួ អនុប្រធានស្ថានីយផលិតកម្ម និងស្រាវជ្រាវ នៅសាលាជាតិកសិកម្មព្រែកលៀប មានប្រសាសន៍ថា ប៉េងប៉ោះមានច្រើនពូជណាស់ ។ ពូជដែលឃើញលក់នៅលើទីផ្សារ គឺនាំចូលពីក្រៅប្រទេស ។ ដូច្នេះលោកគ្រុយ លឹមហួ សំណូមពរថា ប្រជាកសិករគួររកពូជក្នុងស្រុក ដែលមានលក់នៅស្ថានីយស្រាវជ្រាវ និងបង្កាត់ពូជដំណាំបន្លែ នៅឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ព្រោះពួកវាផ្តល់ទិន្នផលខ្ពស់ ។


Photo : L. Samphors

សម្រាប់បច្ចេកទេសដាំដុះវិញ លោកគ្រុយ លឹមហួ រៀបរាប់ថា :

កសិករគួរយកគ្រាប់ពូជ ទៅសាបលើដីខ្សាច់ ដែលបានស្ងោរសម្លាប់មេរោគក្នុងកម្តៅ១០០អង្សារ ជាមុនសិន ។ បន្ទាប់ពីសាបហើយក្នុងរយៈពេលពី ១៥ ថ្ងៃ គួរដកកូនប៉េងប៉ោះទៅដាំក្នុងកន្ទោងដែលមានដាក់ដីជីកំប៉ុស្ត ។ នៅពេលកូនប៉េងប៉ោះរឹងដើម និងស្គាល់ដីថ្មី ទើបកសិករត្រូវដកយកទៅដាំក្នុងចំការក្នុងថ្នាលចន្លោះដើម គឺកន្លះម៉ែត្រ ។ ដីសម្រាប់ដាំប៉េងប៉ោះត្រូវការភ្ជួរ រួចហាលថ្ងៃចោល រយៈពេល ៧ថ្ងៃ មុននឹងរៀបចំថ្នាលដាំប៉េងប៉ោះ ។ ដីដែលល្អបំផុតសម្រាប់ប៉េងប៉ោះ គឺដីល្បាយជូរមាត់ទន្លេ ។

កសិករអាចដាំប៉េងប៉ោះ បានពីររដូវក្នុងមួយឆ្នាំ គឺរដូវវស្សានិងរដូវប្រាំង ។ រដូវវស្សាគឺអាចដាំនៅខែឧសភា មិថុនា កក្កដា និងរដូវប្រាំង ខែតុលា វិច្ឆិកា ធ្នូ ។ នៅរដូវវស្សា កសិករត្រូវស្រោចទឹកប៉េងប៉ោះ ១ដង ក្នុងមួយថ្ងៃ តែបើមានភ្លៀងធ្លាក់ត្រូវរកទឹកស្អាតស្រោចដើម្បីលាងសម្អាត ពីព្រោះភ្លៀងអាចមានជាតិអាស៊ីដ នាំឱ្យមានរោគផ្សិត ។ ចំណែកនៅរដូវប្រាំង កសិករត្រូវស្រោចទឹកពីរដងក្នុងមួយថ្ងៃ គឺនៅព្រឹក និងល្ងាច ។

ជីសម្រាប់ដាក់ប៉េងបោះ គឺកសិករគួរប្រើជីកំប៉ុស្ត ។ កសិករត្រូវដាក់ជីនៅជុំវិញគល់ រួចក៏យកស្លឹកឈើគ្របពីលើ ដើម្បីឱ្យវាជក់សំណើម ។ ប៉េងប៉ោះមានសត្រូវរបស់វា គឺដូចជាជំងឺដង្កូវចោះផ្លែ ស៊ីរូងដើម និងរលួយគល់ ។ យើងត្រូវកំចាត់វាដោយប្រើប្រាស់ថ្នាំពុលធម្មជាតិ ។ ចំណែកជំងឺសេម៉ាតូត បើវាកើតលើដើមណា គឺត្រូវដកវាទៅចោលឱ្យឆ្ងាយពីចំការ ដើម្បីកុំឱ្យវាឆ្លងទៅដើមដទៃ រួចបាចកំបោរកន្លែងខូច និងរកស្លឹកឈើងាប់ដុតដីហ៊ុំងចោលផង ។

ការថែទាំប៉េងប៉ោះ គឺការកាត់មែកគ្មានប្រយោជន៍ចោលដើម្បីធ្វើឱ្យពន្លឺថ្ងៃនិងខ្យល់ចេញចូលស្រួល ។ ប៉ុន្តែកសិករត្រូវធ្វើមុនប៉េងប៉ោះចេញផ្កា ។

## បរិស្ថាន

### ឌីវីឌី អាកាសធាតុ

កាលថ្ងៃទី១ ធ្នូ នៅក្លិបកាសែតបរទេស រាជធានីភ្នំពេញ មានពិធីបង្ហាញ និងសម្ពោធ ឌីវីឌី ស្តីអំពីការប្រែប្រួលអាកាសធាតុដែលរៀបចំដោយក្រុមថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព ឬអង្គការ Geres ។ ឌីវីឌី នេះមាន បីបទ គឺទីមួយ កំណើនកម្តៅផែនដី ទីពីរផលប៉ះពាល់នៃកំណើនកម្តៅផែនដី និងទីបី រួមគ្នាអនុវត្ត ។



Photo : DR

គោលបំណងគឺផ្សព្វផ្សាយដល់សាធារណជនទាំងអស់ យល់ដឹងអំពី បញ្ហានៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ គឺដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម ។ ម្យ៉ាងឌីវីឌីក៏បង្ហាញ ពីវិធីដែលយើងទាំងអស់ត្រូវរួមគ្នាដោះស្រាយដែរ ។

ឯកឧត្តមប្រាជ្ញ ស៊ុន រដ្ឋលេខាធិការក្រសួងបរិស្ថានជាអធិបតីក្នុងពិធី មានប្រសាសន៍ថា កម្ពុជាបានផ្តល់សច្ចាប័ន ដល់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នាឆ្នាំ១៩៩៥ និងបានចូលជាសមាជិករបស់ពិធីសារក្យូតូ នៅឆ្នាំ ២០០២ ។ ដូច្នេះឌីវីឌីអប់រំអំពីអាកាសធាតុនេះ គឺជាវិភាគទានថ្មីមួយទៀត សម្រាប់លើកកម្ពស់នូវចំណេះដឹង ដល់អ្នកធ្វើគោលនយោបាយ និងសាធារណជនទូទៅស្តី អំពីការប្រែប្រួលអាកាសធាតុ និងអំពីតួនាទីរបស់បុគ្គលម្នាក់ៗ ដែលអាចចូលរួមចំណែកបានក្នុងការដោះស្រាយនូវបញ្ហាប្រែប្រួលអាកាសធាតុតាមរយៈសកម្មភាពងាយៗ ។

ប្រសិនបើលោកអ្នក មានបំណងចង់ចូលរួមផ្សព្វផ្សាយ និងស្វែងយល់អំពីបញ្ហាប្រែប្រួលអាកាសធាតុ សូមទំនាក់ទំនងទៅលោកណុប ប៉ូលីន មន្ត្រីសម្របសម្រួលផ្នែកព័ត៌មាន នៃអង្គការ geres ។ ទូរស័ព្ទ : ០១២ ៨៥៧ ៧៣៦ ។



## សុខភាព

# សារធាតុគីមីបន្តគំរាមកំហែងនៅក្នុងអាហារសម្រាប់ពលរដ្ឋកម្ពុជា

**ខាន់ ភីរម្យ**

សារធាតុគីមី ដែលប៉ះពាល់ដល់សុខភាពរបស់អ្នកបរិភោគ ហើយត្រូវបានគេហាមឃាត់ នៅតែត្រូវបានគេរកឃើញ នៅក្នុងអាហារមួយចំនួន ដែលធ្វើតេស្តិ៍សាកល្បងដោយមន្ត្រីជំនាញ ។

យោងតាមរបាយការណ៍ខែវិច្ឆិកា ឆ្នាំ២០០៨ របស់មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ផ្ញើជូនសាលាក្រុង បង្ហាញថា ប្រភេទសារធាតុគីមី ដែលប៉ះពាល់ដល់សុខភាពមនុស្ស មានដូចជាបូរ៉ាក់ និងសូលុយស្យុងអាស៊ីតមួយចំនួន រួមទាំងសារធាតុហ្វ័រម៉ាលីន សារធាតុមីក្រូ និងសារធាតុអេសអេចអេស(SHS) ត្រូវបានមន្ត្រីកាំកុងត្រូល រកឃើញនៅតាមផ្សារនានា នៅក្នុងទីក្រុងភ្នំពេញលើចំណីអាហារមួយចំនួន ។

លោកវេជ្ជបណ្ឌិតមួយរូបនៃមន្ទីរសុខាភិបាល រាជធានីភ្នំពេញ មានប្រសាសន៍ដោយពុំបញ្ចេញឈ្មោះថា សារធាតុដែលគេរកឃើញទាំងអស់នេះ គឺសុទ្ធសឹងតែជាសារធាតុ ដែលបំផ្លាញដល់ប្រព័ន្ធសរីរាង្គ និងធ្វើឱ្យសុខភាពរបស់មនុស្ស មានការចុះខ្សោយ ដែលធ្វើឱ្យពួកគេអាចកើតជាជំងឺមួយចំនួន ដូចជាមហារីកក្រពះ ខូចគ្រលៀន ខូចសរីរាង្គផ្សេងៗ ។

លោកបញ្ជាក់ផងដែរថា : "សារធាតុទាំងអស់នេះ គឺជាសារធាតុគីមីដែលធ្វើឱ្យអាហារមានសោភ័ណភាព ប៉ុន្តែវានឹងធ្វើឱ្យអាហារផ្លាស់ប្តូរពីតួនាទី អ្នកគាំទ្រដល់ការលូតលាស់រាងកាយ ទៅជាប្រភពនៃការបំផ្លាញរាងកាយបាន" ។


Photo : S. Philong

លោកបន្ថែមទៀតថា ជាទូទៅតាមការសិក្សា សារធាតុគីមីបូរ៉ាក់ និងសូលុយស្យុងអាស៊ីត ត្រូវបានគេប្រើប្រាស់នៅក្នុងប្រភេទអាហារគ្រៀមៗ និងផ្អាប់ដើម្បីឱ្យអាហារនោះទុកបានយូរ និងមានសោភ័ណភាព ។ អាហារទាំងនោះ មានដូចជា មីលឿង គុយទាវ បាញ់កាញ់ ប្រហិត សាច់ប៉ាតេ សាច់ក្រក និងត្រីងៀតជាដើម ។ ដោយឡែកសារធាតុហ្វ័រម៉ាលីន គេច្រើនប្រើជាមួយនឹងអាហារស្រស់ៗ ដូចជា ពួកគ្រឿងសមុទ្រជាដើមដើម្បីកុំឱ្យពួកវាស្អុយនិងមានក្លិន ។ ចំពោះសារធាតុដូចជាមីក្រូ គេអាចរកឃើញវានៅក្នុងទឹកសុទ្ធ និងអាហារកំប៉ុងដើម្បីរក្សាទុកបានយូរ ។ ចំណែកសារធាតុគីមី SHS គេច្រើនរកឃើញនៅក្នុងអាហារជ្រក់ដើម្បីកុំឱ្យវាឆាប់ខូច ។

យោងទៅតាមរបាយការណ៍ខាងលើ បានឱ្យដឹងថា នៅគ្រប់ការសិក្សានៅតាមទីផ្សារនៅក្នុងខណ្ឌទាំងចំនួន៧ នៅក្នុងទីក្រុងភ្នំពេញ គេសុទ្ធតែរកឃើញសារធាតុខាងលើទាំងអស់ គឺគ្រាន់តែខ្លះតិច និងខ្លះទៀតច្រើនតែប៉ុណ្ណោះ ។

### អត្រាស្លាប់របស់ជំងឺកញ្ជ្រឹលធ្លាក់ចុះ

អង្គការសុខភាពពិភពលោក ប្រកាសកាលពីដើមខែធ្នូ ឆ្នាំ២០០៨ កន្លងទៅនេះថា អត្រាស្លាប់របស់ជំងឺកញ្ជ្រឹល មានការធ្លាក់ចុះជាសកល។ អង្គការនេះ ប្រកាសថា អត្រាស្លាប់បានធ្លាក់ចុះលើសពី ៧៤ ٪ នៅក្នុងចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧។

តួលេខផ្លូវការអះអាងថា ពីឆ្នាំ២០០០ អត្រាស្លាប់ដោយសារតែជំងឺនេះ មានរហូតដល់ ៧៥០០០០នាក់។ ប៉ុន្តែមកដល់ឆ្នាំ២០០៧ អត្រាស្លាប់បានធ្លាក់ចុះមកនៅត្រឹមតែ ១៩៧០០០នាក់តែប៉ុណ្ណោះ។

តាមរបាយការណ៍នៃការធ្លាក់ចុះនេះ អ្នកជំនាញការរំពឹងថា ផែនការដែលអង្គការសហប្រជាជាតិ បង្កើតឡើងដើម្បីលុបបំបាត់អត្រាអ្នកស្លាប់ដោយសារជំងឺកញ្ជ្រឹល ឱ្យបានលើសពី៩០ ٪ នៅក្នុងឆ្នាំ២០១០ ខាងមុខនេះនឹងបានសម្រេចមុនគោលដៅដែលគេបានគ្រោងដាក់ជាមិនខានឡើយ។

### ជំងឺទាចទឹក


Photo : P. Samphy

លោកវេជ្ជបណ្ឌិតឈៀវ គន្ធារី នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានប្រសាសន៍ថា :

ជំងឺទាចទឹកបង្កឡើងដោយជាតិទឹកជាច្រើន មកផ្តុំគ្នានៅក្នុងស្រោមពោះ ។ ជំងឺនេះគឺបង្កឡើងដោយមូលហេតុច្រើន វាអាចបង្កមកពីមេរោគពួកបាក់តេរី ទាចទឹកបណ្តាលមកពីរលាកថង់ប្រម៉ាត់ ទាចទឹកដែលបណ្តាលមកពីមានដុំនៅក្នុងពោះវៀន និងទាចទឹកបណ្តាលមក ពីរបេងក្រៅស្បូត ឬអ្វីផ្សេងៗ ។ ប៉ុន្តែមូលហេតុសំខាន់បំផុត ដែលបណ្តាលឱ្យកើតទាចទឹក មានពីរគឺ ទីមួយ វាបណ្តាលមកពីជំងឺបេះដូងធ្ងន់ធ្ងរ ដែលធ្វើឱ្យឈាមទៅចាលក្នុងថ្លើមនាំឱ្យកើតជាទាចទឹក និងទីពីរដោយសារថ្លើមមានជំងឺ ។ ចំណែកជំងឺថ្លើមនេះបណ្តាលមកពីយើងផឹកស្រាច្រើនពេក បណ្តាលខូចកោសិកាថ្លើម ដែលនាំឱ្យកើតទាចទឹក ។ រីឯជំងឺថ្លើមប្រភេទបេ និងសេ ក៏នាំឱ្យកើតទាច ទឹកដែរ ។

រោគសញ្ញារបស់ជំងឺទាចទឹក គឺពោះអ្នកជំងឺកាន់តែធំទៅៗ លេចសរសៃឈាមនៅលើពោះ ។ អ្នកជំងឺតឹងឆ្អល់ពោះ ហូបបាយឆាប់ឆ្អែត ញ័រដៃហើមជើង និងពិបាកដកដង្ហើម ។ អ្នកជំងឺថប់ដង្ហើម និងស្លាប់បាន ក្នុងដំណាក់កាលធ្ងន់ធ្ងរបំផុត ។ ដើម្បីការពារទាចទឹក យើងត្រូវចេះរស់នៅដោយមានអនាម័យពិសេសបង្ការមេរោគថ្លើមប្រភេទបេ ដែលវាងាយឆ្លងដូចជាការផឹកទឹកឬស្រាក្នុងកែវរួមគ្នាជាដើម ។ ចំណែកជំងឺថ្លើមប្រភេទសេ គេត្រូវការពារ ដោយពេលរួមភេទត្រូវប្រើស្រោមអនាម័យ ។

លោកវេជ្ជបណ្ឌិតឈៀវ គន្ធារី ផ្តាំផ្ញើថា ទាចទឹកជាជំងឺមួយ ។ វាពុំមែនជាការធ្វើអំពើ ដែលនាំឱ្យពោះធំនោះទេ ។ ភាគច្រើន វាបណ្តាលមកពីជំងឺថ្លើម ។ ដូច្នេះបើមានរោគសញ្ញាដូចបានរៀបរាប់ខាងដើម អ្នកជំងឺគួរទៅរកគ្រូពេទ្យជំនាញជាបន្ទាន់ ដើម្បីឱ្យគាត់វិនិច្ឆ័យរោគ និងព្យាបាលទាន់ពេលវេលា ។

**ផាត សំភី**

January-2009.qxd 12/28/2008 4:22 PM Page 14





Photo : S. Philong

# បង្វិលពពិលក្នុងអាពាហ៍ពិពាហ៍ជនជាតិខ្មែរ

**ខាន់ ភីរម្យ**

លោកសាស្ត្រាចារ្យមៀច ប៉ុណ្ណ ជាទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត មានប្រសាសន៍ថា: ពិធីបង្វិលពពិល គេតែងរៀបចំធ្វើឡើងនៅស្ទើរគ្រប់ពិធីរៀបអាពាហ៍ពិពាហ៍ទាំងអស់ ដែលប្រព្រឹត្តតាមលក្ខណៈប្រពៃណីខ្មែរ។ សារសំខាន់ក្នុងការរៀបចំពិធីនេះ គឺដើម្បីសុំសុខសិរីសួស្តីជូនឱ្យដល់កូនប្រុស និងកូនស្រី ដែលរៀបការជាមួយគ្នា និងអាចចាប់ដៃគ្នារួមរស់ជាស្វាមី និងភរិយាលុះក្ស័យ។

លោកបញ្ជាក់ថា: "វាជាពិធីដែលខ្មែរ មានជំនឿថានឹងចងចំណងអាពាហ៍ពិពាហ៍រវាងបុរសនិងស្ត្រីឱ្យជាប់រហូតដល់ចាស់ លុះត្រាតែស្លាប់រៀងៗខ្លួន"។ លោកក៏គូសបញ្ជាក់ទៀតថា ពិធីនេះខ្មែរយើងរៀបចំឡើង ក៏ដើម្បីរំឭកទៅដល់សាសនា ពីរសំខាន់ៗ គឺលទ្ធិព្រាហ្មណ៍ និងព្រះពុទ្ធសាសនា។

លោករៀបរាប់ដែរថា: "ទៀនតំណាង ឱ្យលិង្គព្រះឥសូរ ឯស្លឹកម្លូ តំណាងឱ្យយូនីនាងឧមាភគវតី ដែលជាភរិយារបស់ព្រះឥសូរ រីឯធម៌ដែលសូត្រដោយអាចារ្យនោះ គឺជាធម៌ព្រះពុទ្ធសាសនា"។

លោកបន្តទៀតថា បើតាមជំនឿរបស់ខ្មែរ លិង្គ និង យោនីនាងឧមានេះ គឺតំណាងឱ្យការបង្កើតលោក ហើយការសូត្រធម៌ព្រះគឺជាការជូនពរសព្វសាធុការដល់គូស្រករថ្មី។ ក្នុងពិធីនេះ អ្នកដែលចូលរួមត្រូវជាមនុស្សប្រុស និងស្ត្រី ដែលមានភ័ព្វ ពោលគឺមានគូ ចំពោះអ្នកដែលគ្មានគូ ឬក៏គេហៅថា បាក់មែកនោះ គេមិនអនុញ្ញាតឱ្យចូលទេ ទោះបីឪពុកម្តាយរបស់កូនប្រុសស្រីក៏ដោយ។

លោកបន្តទៀតថា សម្រាប់ចំនួនបុរសស្ត្រីដែលចូលរួមពិធីនេះ បុរសត្រូវមានចាប់ពី៤នាក់ឡើង ហើយស្រី ចាប់ពីបីនាក់ ឡើងលើ។ បើក្រោមចំនួននេះ គឺមិនបានឡើយពីព្រោះគេថា ខាតលាភ។ នៅក្នុងពិធីនេះ អាចារ្យ យកស្លឹកម្លូដាក់នៅពីមុខកូនប្រុស និងកូនស្រី ហើយគេក៏បង្វិលទៀនដែលដុតឱ្យឆេះនៅជុំវិញដោយមនុស្សមានភ័ព្វទាំងអស់ ដោយពួកគេត្រូវទទួលដោយដៃឆ្វេង ហើយប្រើដៃស្តាំបក់ផ្សែងទៀន ដោយប្រើកាយវិការ ដូចជាកួចចំណង ជានិមិត្តរូបនៃការចងភ្ជាប់ទំនាក់ទំនងរវាងកូនប្រុស និងស្រី កុំឱ្យស្រាយចំណងនេះរួច។ ការបង្វិលរបៀបនេះ គឺធ្វើឡើងចាប់ពី ៩ជុំ ឡើងទៅរហូតដល់ ១៩ជុំ។ ចំណែកកូនកម្លោះក្រមុំដែលកំពុងតែរៀបអាពាហ៍ពិពាហ៍នោះ គេតម្រូវឱ្យស្រូបផ្សែងនេះដើម្បីឱ្យបានទទួលសិរីសួស្តីទៅថ្ងៃក្រោយ។

## អំណាន

### រឿងកោះសុបិន



គឺជាវណ្ណកម្មប្រលោមលោកមួយរបស់លោកនេត ចម្រើន ដែលអាចចាត់ទុកថាជាអ្នកនិពន្ធអាជីពម្នាក់។ ស្នាដៃជាច្រើនរបស់គាត់ គឺតែងតែបង្កប់នូវចំណុចអវិជ្ជមាន មួយចំនួនរបស់មនុស្ស ដើម្បីឱ្យអ្នកអានយកទៅរិះគិតពិចារណា។ សម្ពន្ធមេត្រីរវាងណារ៉ា និងដាណែតជាស្នេហាស្មោះស្ម័គ្រ តែជាស្នេហាដែលទំនាស់នឹងរបងវណ្ណៈ និងក្បត់ប្រពៃណី។ ទុក្ខសោកទាំងឡាយដែលបានកើតឡើងចំពោះតួអង្គទាំងអស់ តើគួរបន្ទោសអ្នកណា? មាតាបិតា ឬសាមីខ្លួន? "កោះសុបិន" នឹងនាំអ្នកអានទាំងអស់ទៅ ស្វែងយល់អំពីជីវិតស្នេហាដ៏អភ័ព្វរបស់តួអង្គឯកទាំងពីរ។

ថ្វីត្បិតតែប្រវត្តិស្នេហ៍របៀបនេះ មិនមែនជាប្រធានបទថ្មីនៅក្នុងកម្រងប្រលោមលោកខ្មែរក៏ដោយ ក៏រឿងនេះនៅតែធ្វើឱ្យអ្នកអាន មានអារម្មណ៍រំភើបរន្ធត់ ស្របទៅតាមចង្វាក់សាច់រឿងដែរ ពីព្រោះអ្នកនិពន្ធចេះច្នៃសាច់រឿងឱ្យមានភាពរស់រវើក និងស្តែងឱ្យឃើញពីតថភាពនៃសង្គមបច្ចុប្បន្ននេះ។ រឿងនេះមានកម្រាស់១០៣ ទំព័រ។

### ពេលដែលគ្មានអូន



ជាកម្រងរឿងមនោសញ្ចេតនា ឆ្លុះបញ្ចាំង ពីជីវិតស្នេហារបស់យុវជនមួយចំនួន ដែលស្ថិតក្នុងវ័យ ដ៏ក្មេងខ្ចី។ ថ្វីត្បិតលោកសួយ ឡូត ដែលជាអ្នកនិពន្ធរឿងនេះ បានអះអាងថា នេះគឺជារឿងប្រឌិតទាំងស្រុងក៏ដោយ ក៏រឿង "ពេលដែលគ្មានអូន" មានបង្កប់នូវតថភាពក្នុងសង្គមជាច្រើនជាពិសេស គឺសង្គមយុវវ័យតែម្តង។

ប្រលោមលោកនេះត្រូវបានសរសេរ ដោយប្រើពេលអស់ជិតដប់ឆ្នាំ គឺតាំងពីអ្នកនិពន្ធនៅជាយុវវ័យម្ល៉េះ ប្រហែលជាដោយសារហេតុនេះហើយ ទើបគាត់អាចសរសេរបានយ៉ាងល្អពីអារម្មណ៍ និងការគិតពីទង្វើរបស់យុវជនបាន។ ខុសប្លែកពីស្នេហារបស់ទុំទាវ ឬស្នេហាប៊ុនធឿន និងវិធាវី ស្នេហាសារុន និងសោភា ដែលជាតួអង្គឯកប្រុសស្រី ក្នុងរឿងនេះ គឺជាស្នេហាដែលជួបឧបសគ្គ ព្រោះតែសាមីខ្លួនផ្ទាល់។ តើវិបត្តិស្នេហ៍របស់អ្នកទាំងពីរគឺកើតឡើងដោយរបៀបណា? "ពេលដែលគ្មានអូន" នឹងបកស្រាយចម្ងល់នេះជូនមិត្តអ្នកអានទាំងអស់ ហើយរឿងនេះនឹងផ្តល់ដល់អ្នកនូវគំនិតមួយចំនួនសម្រាប់យកទៅរិះគិតពិចារណា។ រឿងនេះមានកម្រាស់ ១២៧ទំព័រ។

**ម៉េង សុមនា**





# ស៊ូដង់ ស្ដេចផារ៉ាអុងដល់សង្គ្រាមដាហ្វួ

**អាន ឡូរ៉ំ ប៉ូរ៉េ**




Photos : DR

ប្រទេសស៊ូដង់ ជាប្រទេសដែលធំជាងគេបង្អស់នៅទ្វីបអាហ្វ្រិក។ ស៊ូដង់គឺជាវាលទំនាបដ៏ធំមួយដែលអមដោយប្រជុំភ្នំដ៏ច្រើននៅភាគខាងលិច និងខាងកើតប្រទេស។ នៅភាគខាងជើង វាគឺជាវាលរហោឋាន។ ប៉ុន្តែប្រជាជនស៊ូដង់រស់នៅ ដោយពឹងផ្អែកលើរបរកសិកម្ម។ ដូចជាប្រទេសអេស៊ីបដែរស៊ូដង់មានទន្លេធំមួយហូរឆ្លងកាត់ គឺទន្លេនីល។ ហើយក៏ដូចជនជាតិអេស៊ីប ជនជាតិស៊ូដង់មានមោទនភាពពីព្រះចៅផារ៉ាអុង និងពីរ៉ាមីដនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ រឿងនេះអាចពន្យល់បានតាមរយៈការជះឥទ្ធិពលទៅមក រវាងប្រទេសពីរនេះ តាមរយៈពេលវេលាសម្រាប់ទំនាក់ទំនងនៃពាណិជ្ជកម្មដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកនៅក្នុងបរិយាកាសសន្តិភាព ឬសង្គ្រាមគ្រប់គ្រងគ្នាទៅមក។

នាសតវត្សរ៍ទី៦ ព្រះរាជាណាចក្រតូចៗទាំងឡាយបានប្រែក្លាយបន្តិចម្តងៗ ទៅកាន់សាសនាគ្រីស្ត។ តែព្រះរាជាណាចក្រទាំងនេះត្រូវ ស្ថិតនៅក្នុងភាពឯកោ ដោយសារតែជនជាតិអារ៉ាប់ ដែលបានវាយច្បាំងដណ្តើមយកបាននូវប្រទេសអេហ្ស៊ីប និងកាត់ផ្តាច់ទំនាក់ទំនងរវាងព្រះសហគមន៍កាតូលិកស៊ូដង់ និងព្រះសហគមន៍កាតូលិកអេហ្ស៊ីប ដែលវាជាការអនុគ្រោះយ៉ាងខ្លាំងដល់ការរីកសាយភាយខ្លាំងក្លានៃសាសនាអ៊ិស្លាម។ ដោយសារតែជនជាតិអារ៉ាប់នេះហើយ ដែលប្រទេសស៊ូដង់ ប្រកាន់យកឈ្មោះរបស់ខ្លួន។ ជនជាតិអារ៉ាប់ហៅទឹកដីនេះ "bilad el sudan" "ប៊ីឡាដ អែល ស៊ូដង់" ដែលមានន័យជាភាសាអារ៉ាប់ថា "ប្រទេសនៃជនជាតិស្បែកខ្មៅ"។

សតវត្សរ៍ទី១៩ មានភាពតានតឹងជាមួយ ប្រទេសអេស៊ីប អ្នកជិតខាងមានភាពខ្លាំងក្លា: មេដឹកនាំអេហ្ស៊ីបមហាម៉ាត់ អាលី ក៏ចង់ច្បាំងដណ្តើមយកប្រទេសស៊ូដង់។ ជនជាតិអង់គ្លេស ដែលព្យាយាមពង្រីកឥទ្ធិពលអាណានិគមរបស់ខ្លួន និងដែលគាំទ្រប្រទេសអេហ្ស៊ីប តាំងពីយូរយារណាស់មកហើយ បានបញ្ជូនទាហាន ដើម្បីទៅបង្ក្រាបប្រទេសស៊ូដង់ និងបែងចែកការគ្រប់គ្រងទឹកដីនេះជាមួយនិងជនជាតិអេហ្ស៊ីបរហូតដល់ឆ្នាំ១៩៥៦ ដែលជាការបរិច្ឆេទឯករាជ្យរបស់ស៊ូដង់។

### ហេតុអ្វីបានមានជម្លោះនេះ?



នៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ នៅភាគខាងលិចប្រទេសស៊ូដង់មានជួបគ្រោះរាំងស្ងួត និងកំណើនយ៉ាងខ្លាំងក្លានៃចំនួនប្រជាជន។ នេះគឺជាស្ថានភាពអនុគ្រោះដល់ការកើនឡើងនូវភាពតានតឹនរវាងប្រជាជន និងការមិនទុកចិត្តចំពោះអំណាចរបស់រដ្ឋាភិបាលក្រុងកាទុម។ ចំណែកសង្គ្រាមបង្ហូរឈាមនៅប្រទេសឆាដ (Tchad) បានរាលដាលឆ្លងចូលមកប្រទេសស៊ូដង់ ហើយសេចក្តីស្រេកឃ្លានរបស់ប្រទេសមួយចំនួនដូចជាចិន ឬសហរដ្ឋអាមេរិកចំពោះប្រេងកាតរបស់ស៊ូដង់ ក៏បានចូលរួមយ៉ាងធំធេងដល់ការរីករាលដាលនៃជម្លោះ។

ចាប់តាំងពីមានឯករាជ្យ បណ្តាលខេត្តនៅភាគខាងត្បូងប្រទេសកម្រើកសុំស្វ័យភាព។ ពួកគេក៏ទទួលបានស្វ័យភាព នៅឆ្នាំ១៩៧២ ហើយក៏ជាការចាប់ផ្តើមសង្គ្រាមស៊ីវិលដែរ។ ឧទ្ទាមកម្មបានរីករាលដុះដាលយ៉ាងខ្លាំង ក្រោយពីការបង្កើត ច្បាប់អ៊ិស្លាមស្សារីយ៉ា (Charia) នៅឆ្នាំ១៩៨៣។ នៅប្រទេសស៊ូដង់ជម្លោះ គឺមិនងាយនឹងថមថយចុះបានឡើយ ដោយសារជម្លោះខាងសាសនា។

រដ្ឋប្រហារដែលធ្វើឡើងដោយលោកអូម៉ា អែលបេហ្សៀ (Omar el-Bechir) នៅឆ្នាំ១៩៨៩ រឹតធ្វើឱ្យជម្លោះរីកកាន់តែរីកធំ។ នៅឆ្នាំ២០០៣សង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅដាហ្វួ។ រដ្ឋាភិបាលនៅក្រុងកាទូម(Khartoum) គាំទ្រកងកម្លាំងហ្សានហ្សាវីដ ដែលសាបព្រោះនូវសេចក្តីភ័យខ្លាចនៅក្នុងចំណោមប្រជាជនស៊ីវិលដោយពួកគេប្រកាន់យកការតស៊ូតាមរបៀបឧទ្ទាម ដែលបណ្តាលឱ្យមនុស្សជាច្រើនស្លាប់។ សង្គ្រាមស៊ីវិលបានធ្វើឱ្យប្រជាជនរាប់លាននាក់ភៀសខ្លួន និងសេដ្ឋកិច្ចត្រូវជាប់គាំង ដែលនាំទៅដល់គ្រោះទុរ្ភិក្សក្នុងចំណោមប្រជាជន។

អំឡុងរយៈពេលជាច្រើនឆ្នាំ សហភាពអាហ្វ្រិកនិងអង្គការសហប្រជាជាតិ ក៏មានគោលបំណងចូលធ្វើអន្តរាគមន៍។ ហើយទីបំផុតកម្លាំងអន្តរាគមន៍ត្រូវទទួលឱ្យចូលទៅធ្វើការនៅក្នុងប្រទេសស៊ូដង់ដែលបេសកកម្មរបស់ពួកគេ គឺថែរក្សាប្រជាជន។ ប៉ុន្តែសង្គ្រាមនៅតែបន្តមិនទាន់បញ្ចប់។




សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។

អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ_កម្ពុជា ឫទូរស័ព្ទ : ០២៣ ២១៦ ០០១។

# កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

ជាកម្មវិធីមួយដែលរៀបចំឡើងក្នុងការបង្ហាញផ្លូវ
និងរកដំណោះស្រាយដល់មិត្តយុវវ័យ ជាពិសេសនិស្សិត
ដែលកំពុងតែសិក្សានៅមហាវិទ្យាល័យ
និងស្វែងរកការងារធ្វើ ។
កម្មវិធីនេះមានការផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ និងអង្គារ៍
វេលាម៉ោង ១០-១១ព្រឹក នៅវិទ្យុគ្រួសារ
**FM 99.5 Mhz** រាជធានីភ្នំពេញ ។

## ការងារប្រចាំខែ

- ដើមខែមករា ឆ្នាំ២០០៩ : ក្រុមនៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច នៅរាជធានីភ្នំពេញ ចុះជួសជុលផ្ទះជូនអ្នកក្រក្រី ដែលថវិកាបានមកពីការប្រមូលពីសប្បុរសជននានានៅក្នុងប្រទេសកម្ពុជា។
- ថ្ងៃទី០១-០៥ មករា : មានការប្រជុំរបស់ក្រុមសាសនទូតជនជាតិ និយាយអំពីជីវិតជាអ្នកបម្រើនៅប្រទេសកម្ពុជា នៅក្រុងព្រះសីហនុ។
- ថ្ងៃទី០៧ មករា : សកម្មភាពពិធីជប់លៀងឱ្យក្មេងអនាថា ចំនួន១០០នាក់ ដោយមានការចូលរួមពីក្រុមវ៉ាំងសង់ ឌឺ ប៉ូល និងមណ្ឌលយុវជនក្រុងកំពង់ចាម។
- ថ្ងៃទី០១ មករា : ប្រជុំគ្រីស្តបរិស័ទនៅព្រះសហគមន៍កោះរកាភូមិភាគកំពង់ចាម ស្តីអំពីសន្តប៉ូល ដោយមានអ្នកចូលរួមចំនួន ៧០នាក់។
- ថ្ងៃទី០៣-០៤ មករា : សិក្ខាសាលាដល់ក្រុមយុវជនភូមិភាគភ្នំពេញ អំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហ-គមន៍ នៅមណ្ឌលសកម្មភាពតាកែវ។
- ថ្ងៃទី០៤ មករា : បុណ្យខួបលើកទី២១៩ របស់ព្រះសហគមន៍ខេត្តបាត់ដំបង។
- ថ្ងៃទី១០-១១ មករា : សិក្ខាសាលាដល់ក្រុមយុវជនភូមិភាគភ្នំពេញ អំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហ-គមន៍នៅមណ្ឌលសកម្មភាពបឹងទំពុន។
- ថ្ងៃទី១៤ មករា : ជំហានទី១ សម្រាប់កូនក្មេងចំនួន ២០នាក់ នៅម៉ោង៨ ពេលព្រឹក នៅព្រះវិហារសន្តយ៉ូសែបផ្សារតូច។
- ថ្ងៃទី១៤ មករា : ជំហានទី១ សម្រាប់យុវជនចំនួន ១០នាក់ ម៉ោង ៥រសៀល នៅព្រះវិហារសន្តយ៉ូសែប។
- ថ្ងៃទី២៤-២៥ មករា : សិក្ខាសាលាដល់ក្រុមយុវជនភូមិភាគភ្នំពេញ អំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហ-គមន៍នៅមណ្ឌលសកម្មភាពក្រុងព្រះសីហនុ។
- ថ្ងៃទី២៤-២៥ មករា : សិក្ខាសាលាដល់ក្រុមយុវជនភូមិភាគភ្នំពេញអំពីការឆ្លុះបញ្ចាំងខ្លួនឯង និងបេសកកម្មរបស់យុវជនក្នុងព្រះសហ-គមន៍នៅមណ្ឌលសកម្មភាពក្រុងព្រះសីហនុ។
- ថ្ងៃទី២៦-៣១ មករា : ប្រជុំប្រចាំឆ្នាំអ្នកណែនាំពេញវ័យនៅព្រះសហគមន៍ក្រុងព្រះសីហនុ ដែលរៀបចំឡើងដោយគណៈកម្មាធិការអប់រំជំនឿមនុស្សពេញវ័យអន្តរភូមិភាគ។